ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និង អនុវិទ្យាល័យក្នុងប្រទេសកម្ពុជា ករណីសិក្សា៖ ខេត្តមណ្ឌលគិរី

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT PRIMARY AND SECONDARY SCHOOLS IN CAMBODIA. A CASE STUDY IN MONDULKIRI PROVINCE.

ដោយ /By

ម៉ោញ រដ្ឋា / MONH RATHA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ( ជំនាន់ទី៣ )

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា ករណីសិក្សា៖ ខេត្តមណ្ឌលគិរី

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT PRIMARY AND SECONDARY SCHOOLS IN CAMBODIA. A CASE STUDY IN MONDULKIRI PROVINCE.

ដោយ / By

ម៉ោញ រដ្ឋា / MONH RATHA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ (ជំនាន់ទី៣)

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩. ២០២០

សាស្ត្រាចារ្យដឹកនាំ ៖ លោក សៀង ខាសនា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំឈ្មោះ **ម៉ោញ រដ្ឋា** សូមបញ្ជាក់ថា ការសិក្សាស្រាវជ្រាវនិក្ខេបបទមានចំណងជើងថា **«ស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា» ករណីសិក្សាខេត្តមណ្ឌលគិរី** ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ពិតជាកិច្ចការរបស់នាងខ្ញុំ ដែលមានភាពដើមទាំងស្រុងពិតប្រាកដមែន ។ ស្នាដៃនៃការសិក្សាស្រាវជ្រាវនេះ គឺពិតជាកើតឡើងដោយសារតែការព្យាយាម ខិតខំប្រឹងប្រែង ព្រមទាំងបានចំណាយពេលវេលាជាច្រើនខែ ក្នុងការចុះប្រមូលយកទិន្នន័យដោយពុំមានចម្លងតាមឯកសារណាមួយឡើយ។

ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២១

**ហត្ថលេខា**

**ម៉ោញ រដ្ឋា**

**លិខិតបញ្ជាក់**

**លោក សៀង វាសនា ជាសាស្ត្រាចារ្យដឹកនាំ**

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

ក្នុងនាមជាសាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទស្រាវជ្រាវរបស់និស្សិតវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដែលមានប្រធានបទ “**ស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា” ករណីសិក្សា៖ ខេត្តមណ្ឌលគិរី**

សូមបញ្ជាក់ថាបេក្ខជនឈ្មោះ **ម៉ោញ រដ្ឋា** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើពិតប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២១

**សាស្ត្រាចារ្យដឹកនាំ**

**សៀង វាសនា**

គ្រូឧទ្ទេស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខៈ.......✓........ វជអ.

# លិខិតបញ្ជាក់ និងទទួលស្គាល់

## នាយកវិទ្យាស្ថានជាតិអប់រំ

## សូមបញ្ជាក់ និងទទួលស្គាល់ថាៈ

លោកស្រី **ម៉ោញ រដ្ឋា** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ **"ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា" ករណីសិក្សាៈ ខេត្តមណ្ឌលគិរី** ដែលស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាល ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខៈ៣៣៤.....វជអ. ឧក

**លិខិតឧទ្ទេសនាម**

យោងៈ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី រដ្ឋា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ទី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ វ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្លន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន រ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១៧/៨៥៤ គេហទំព័រៈ www.nie.edu.kh

II. **លេខាធិការដ្ឋាន** ( កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ )

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្រ្តីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្រ្តីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្រ្តីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្រ្តីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្រ្តីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** ( រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍ )

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវេជអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវេជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវេជអ

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉ោញ រដ្ឋា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំ ។

សូមថ្លែងអំណរគុណជាអនេកចំពោះ៖

– លោកឪពុក **ម៉ោញ ចេង** និងអ្នកម្ដាយ **ឯម គែច** ជាអ្នកមានគុណដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីថ្នាក់មត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សាដោយមិនគិតពីការលំបាកនឿយហត់ ព្រមទាំងតស៊ូគ្រប់បែបយ៉ាងដើម្បីកូនទទួលបានចំណេះដឹង និងមានអនាគតល្អដូចសព្វថ្ងៃនេះ ។

– លោកឪពុកក្មេក **ផាន់ ចន្ថា** និងអ្នកម្ដាយក្មេក **ស្រេង ស្រ៊ីម** ជាអ្នកមានគុណទីពីរដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់នូវដំបូន្មានល្អៗដល់ស្វាមី និងបានជួយជ្រោមជ្រែងផ្នែកស្មារតី និងការលើកទឹកចិត្តឱ្យនាងខ្ញុំបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ។

– លោក**ផាន់ ច័ន្ទថន**ជាស្វាមី និងបុត្រា បុត្រីទាំងពីររបស់នាងខ្ញុំ ដែលបានជួយជាកម្លាំងកាយ កម្លាំងចិត្ត និងការជម្រុញលើកទឹកចិត្តឱ្យនាងខ្ញុំបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ។

– បងប្អូនរបស់នាងខ្ញុំទាំងអស់ដែលតែងតែជួយផ្ដល់នូវថវិកា ស្មារតី ជាពិសេសកម្លាំងចិត្តក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានជោគជ័យ ។

– ឯកឧត្ដមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងការផ្ដល់ឱកាសឱ្យមន្ត្រីអប់រំបានអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែម ។

- ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណារា** នាយកវិទ្យាស្ថានជាតិអប់រំ លោក លោកស្រីជាសាស្ត្រាចារ្យ បុគ្គលិក នៃវិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់ បង្រៀនរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ ។

- ឯកឧត្តម លោកគ្រូ អ្នកគ្រូ ដែលជាគ្រូឧទ្ទេសថ្នាក់ក្រសួងទាំងអស់ដែលបានបង្រៀនប្រកបដោយការយកចិត្តទុកដាក់ និងលះបង់ពេលវេលាដ៏មានតម្លៃមកបណ្តុះបណ្តាលរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ ។

- សាស្ត្រាចារ្យដឹកនាំលោក **សៀង ខាសនា** ដែលបានផ្តល់គំនិតណែនាំ និងផ្តល់ទាំងកម្លាំងចិត្តប្រាជ្ញាស្មារតី បច្ចេកទេសវិធីសាស្ត្រ និងឯកសារផ្សេងៗរហូតទទួលបានជោគជ័យ ។

ជាចុងបញ្ចប់នាងខ្ញុំសូមគោរពជូនពរ ក្រុមគ្រួសាររបស់ខ្ញុំ លោក លោកស្រី ជាសាស្ត្រាចារ្យ និងបុគ្គលិកវិទ្យាស្ថានជាតិអប់រំ និងឯកឧត្តម លោក លោកស្រីទទួលបានសេចក្តីសុខ មានសុខភាពល្អបរិបូរណ៍ កម្លាំងពលំ មាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

ទំព័រ

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ........ i
**លិខិតបញ្ជាក់ សាស្ត្រាចារ្យដឹកនាំ** ........ ii
**លិខិតបញ្ជាក់ និងទទួលស្គាល់** ........ iii
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ iv
**សេចក្តីថ្លែងអំណរគុណ** ........ vi
**មាតិកា** ........ viii
**បញ្ជីតារាង** ........ xii
**បញ្ជីរូបភាព** ........ xiii
**មូលន័យសង្ខេប** ........ xiv
**ជំពូកទី១ សេចក្តីផ្តើម** ........ 1
១.១.សេចក្តីផ្តើម ........ 1
១.២.លំនាំបញ្ហានៃការស្រាវជ្រាវ ........ 3
១.៣ ចំណោទបញ្ហានៃការស្រាជ្រាវ ........ 3
១.៤. គោលបំណងនៃការស្រាវជ្រាវ ........ 4
១.៥. សំណួរស្រាវជ្រាវ ........ 4
១.៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ 5
១.៧. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 5
១.៧.១.វិសាលភាពនៃការស្រាជ្រាវ ........ 5
១.៧.២.ដែនកំណត់នៃការស្រាវជ្រាវ ........ 5
១.៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 6
**ជំពូកទី២ រំឭកទ្រឹស្តី** ........ 8
២.១. សេចក្តីផ្តើម ........ 8

២.២. កាតព្វកិច្ចត្រូវបំពេញ និងតួនាទីរបស់ខ្លួន ......9
២.៣. សារៈសំខាន់នៃការគ្រប់គ្រង និងដឹកនាំអង្គភាព ......9
២.៣.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ ......10
២.៣.២. ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា ......11
២.៣.៣. ការរៀបចំផែនការក្របខ័ណ្ឌប្រចាំឆ្នាំ ......11
២.៣.៤. ការជ្រើសរើសបុគ្គលិកចូលក្របខ័ណ្ឌ ......12
២.៣.៥. ដំណោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន ......13
២.៣.៥.១ សាលារៀនលើសគ្រូបង្រៀន ......13
២.៣.៥.២ សាលារៀនខ្វះគ្រូបង្រៀន ......13
២.៣.៥.៣ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា ......14
២.៣.៥.៤ ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន ......14
២.៣.៥.៥ ពង្រឹងប្រសិទ្ធភាព ជាអ្នកដឹកនាំសាលា ......15
២.៤. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា និងម៉ោងបំពេញការងារបុគ្គលិកអប់រំ ......15
២.៤.១. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា......15
២.៤.២. ការកំណត់ម៉ោងបំពេញការងារបុគ្គលិកអប់រំ ......15
២.៥ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀន ......17
២.៥.១ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកក្នុងរាជធានី/ខេត្ត ......17
២.៥.២ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកឆ្លងរាជធានី/ខេត្ត......18
២.៥.៣ ការផ្លាស់ប្តូរតាមសហព័ន្ធ......18
២.៦ ការបែងចែកគ្រូបង្រៀនតាមគ្រឹះស្ថានសិក្សា ......19
គ្រឹះស្ថានសិក្សាចំណោះទូទៅ ......19
២.៦.១. ការបែងចែកភារកិច្ចសម្រាប់បុគ្គលិកបង្រៀន ......19
២.៦.២ ការអនុវត្តម៉ោងបន្ថែមសម្រាប់បុគ្គលិកបង្រៀនមធ្យមសិក្សា......20
២.៦.៣ ការប្រើប្រាស់បុគ្គលិកនៅទីចាត់ការនៃសាលារៀន ......21
២.៦.៤ ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនដែលទទួលបន្ទុកថ្នាក់......21

២.៦.៥ ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនច្រើនកម្រិត ឬច្រើនមុខវិជ្ជា................22
២.៦.៦.ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនជាប្រធានក្រុមបច្ចេកទេសមុខវិជ្ជានៅសាលាកម្រង សាលាមធ្យមសិក្សាធនធាន ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ..................22
២.៦.៧.និយាមប្រើប្រាស់បុគ្គលិក ម៉ោងកំណត់ និងម៉ោងបន្ថែម.........................................22
**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ**..........................................................................................24
៣.១ ដំណើរការនៃការស្រាវជ្រាវ ......................................................................................24
៣.២ ការជ្រើសរើសគំរូសំណាក ........................................................................................24
៣.៣ ឧបករណ៍ស្រាវជ្រាវ និងការប្រមូលទិន្នន័យ ...................................................................27
៣.៣.១ ឧបករណ៍ស្រាវជ្រាវ ..............................................................................................27
៣.៣.២ ការប្រមូលទិន្នន័យ................................................................................................27
៣.៤ វិធីសាស្ត្រវិភាគទិន្នន័យ.............................................................................................28
៣.៥ និតិវិធី (ក្រមសីលធម៌) ឬដំណើរការប្រមូលទិន្នន័យ .......................................................28
**ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ** ................................................................................30
៤.១. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា .......................................................30
៤.១.១. ស្ថានភាពទីតាំងសាលាបឋមសិក្សា..........................................................................30
៤.១.២. ការកំណត់ពីតម្រូវការគ្រូបឋមសិក្សា.........................................................................30
៤.១.២.១. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាទូទាំងខេត្ត ..................30
៤.១.២.២. ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាក្រុងសែនមនោរម្យ .................32
៤.១.២.៣. ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកអូររាំង..........................33
៤.១.២.៤. ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកកោះញែក.......................35
៤.១.២.៥. ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកពេជ្រាដា .......................36
៤.១.២.៦.ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកកែវសីមា........................37
៤.១.៣. ទស្សនៈរបស់នាយក/នាយិកាលើការប្រើប្រាស់គ្រូនៅបឋមសិក្សា ...........................38
៤.២. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ...................................................41
៤.២.១. ស្ថានភាពទីតាំងសាលារៀនសម្រាប់អនុវិទ្យាល័យ ..................................................41

៤.២.២.ការកំណត់ពីតម្រូវការគ្រូ នៅអនុវិទ្យាល័យ (តាមនិយាមថ្មីលេខ២០)........................41
៤.២.២.១.ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅអនុវិទ្យាល័យទូទាំងខេត្តមណ្ឌលគិរី............41
៤.២.២.២.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងក្រុងសែនមនោរម្យ..................................44
៤.២.២.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកអូររាំង..............................................45
៤.២.២.៤.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកកោះញែក...........................................46
៤.២.២.៥.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកពេជ្រាដា.............................................48
៤.២.២.៦.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកកែវសីមា.............................................49
៤.២.៣. ការកំណត់ពីតម្រូវការគ្រូ នៅអនុវិទ្យាល័យ (តាមនិយាម លេខ២៥៦).....................50
៤.២.៤. ទស្សនៈរបស់នាយក/នាយិកាលើការប្រើប្រាស់គ្រូអនុវិទ្យាល័យ...............................53
៤.២.៥.បញ្ហាប្រឈម និងដំណោះស្រាយរបស់នាយក/នាយិកាលើការប្រើប្រាស់គ្រូបង្រៀន .....54
៤.២.៦.មតិយោបល់បន្ថែមរបស់នាយក/នាយិកា លើការប្រើប្រាស់គ្រូបង្រៀន........................56
**ជំពូកទី៥ សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍** ..............................................57
៥.១. សេចក្តីសន្និដ្ឋាន.................................................................................................57
៥.២. សំណូមពរ .........................................................................................................58
៥.៣. អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត..............................................................59
**ឯកសារយោង**(REFERENCE)...................................................................................61
**ឧបសម្ព័ន្ធ** ........................................................................................................63

# បញ្ជីតារាង

**ទំព័រ**


តារាងទី១៖ ចំនួនសាលាបឋមសិក្សានិងអនុវិទ្យាល័យទូទាំងខេត្តមណ្ឌលគិរី ....................................6

តារាងទី២៖ ប្រភេទគ្រឹះស្ថានសិក្សា....................................................................................................15

តារាងទី៣៖ ម៉ោងបំពេញការងារបុគ្គលិកអប់រំ ...................................................................................15

តារាងទី៤៖ រដ្ឋបាលខេត្តមណ្ឌលគិរី....................................................................................................26

តារាងទី៥៖ សាលារៀនដែលស្ថិតនៅតំបន់ទីប្រជុំជន តំបន់ជនបទ និងតំបន់ជួបការលំបាក..............30

តារាងទី៦៖ សាលារៀនដែលស្ថិតនៅតំបន់ទីប្រជុំជន តំបន់ជនបទ និងតំបន់ជួបការលំបាក.............. 41

តារាងទី៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង ................................ 41

តារាងទី៨៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងក្រុងសែនមនោរម្យ..44

តារាងទី៩៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកអូររាំង ...........45

តារាងទី១០៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកកោះញែក ...46

តារាងទី១១៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកពេជ្រាដា .....48

តារាងទី១២៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកកែវសីមា.....49

តារាងទី១៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង គ្រូសរុបតាមនិយាមចាស់ និងតាមជាក់ស្តែងទូទាំងខេត្ត...........50

# បញ្ជីរូបភាព

ទំព័រ

ក្រាហ្វទី១៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង ....................................................30

ក្រាហ្វទី២៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង ....................................................32

ក្រាហ្វទី៣៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង ....................................................33

ក្រាហ្វទី៤៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង ....................................................34

ក្រាហ្វទី៥៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០(ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង ....................................................36

ក្រាហ្វទី៦៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥ (សិស្សថ្នាក់ទី១-៣) ៤០(សិស្សថ្នាក់ទី៤-៦) និយាមអតិបរមា ៤៥(សិស្សថ្នាក់ទី១-៣) ៥០(សិស្សថ្នាក់ទី៤-៦) និងតាមជាក់ស្តែង ..37

ក្រាហ្វទី៧៖ ការស្នើសុំគ្រូរយៈពេល៥ឆ្នាំចុងក្រោយ ....................................................38

ក្រាហ្វទី៨៖ ដំណោះស្រាយបញ្ហាប្រឈមលើស ឬខ្វះគ្រូ របស់នាយក/នាយិកាសាលា......................39

ក្រាហ្វទី៩៖ អនុសាសន៍របស់នាយកសាលា ចំពោះក្រសួងអប់រំ យុវជន និងកីឡា ..........................40

ក្រាហ្វទី១០៖ ស្ថិតិ គ្រូជាក់ស្តែង តាមនិយាមថ្មី និងលើស ឬខ្វះគ្រូ ............................................43

ក្រាហ្វទី១១៖ ស្ថិតិ គ្រូជាក់ស្តែង តាមនិយាមចាស់ និងលើស ឬខ្វះគ្រូ............................................52

ក្រាហ្វទី១២៖ ការស្នើសុំគ្រូរយៈពេល៥ឆ្នាំចុងក្រោយ....................................................53

# មូលន័យសង្ខេប

ពេលកន្លងមកមានបញ្ហាមួយចំនួន កើតមានឡើងនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានា នៅក្នុងខេត្តមណ្ឌលគិរី ទាក់ទងនឹងការបែងចែក និងប្រើប្រាស់គ្រូបង្រៀនមិនទាន់សមស្របតាមនិយាមសិស្ស ថ្នាក់ គ្រូ និងតាមមុខវិជ្ជា ដែលធ្វើឱ្យសាលាទាំងនោះជួបបញ្ហាប្រឈមដូចជា៖ ខ្វះគ្រូនៅតាមសាលាតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក លើសគ្រូនៅតំបន់ទីប្រជុំជន និងការប្រើប្រាស់គ្រូខុសឯកទេស ធ្វើឱ្យប្រាក់ម៉ោងបន្ថែមកើនឡើងនៅតាមសាលា ជាហេតុឱ្យប៉ះពាល់ដល់គុណភាពអប់រំ នៅក្នុងខេត្តក៏ដូចជានៅទូទាំងប្រទេស។

ការសិក្សាស្រាវជ្រាវនេះតម្រូវយកសាលា ទាំងអស់ក្នុងខេត្តមណ្ឌលគិរី មាន៥ក្រុង/ស្រុក ដែលធ្វើឡើងនៅតាមសាលាបឋមសិក្សា៨៨ និងអនុវិទ្យាល័យ៩ ដែលក្នុងនោះមានវិទ្យាល័យនៅជាមួយចំនួន០៥ក្នុងខេត្ត។ អ្នកដែលត្រូវចូលរួមផ្តល់ព័ត៌មាននេះ មានមន្ទីរ ការិយាល័យស្រុក នាយក/នាយិកាសាលាទាំងអស់ រាល់ព័ត៌មានលម្អិត ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនតាមសាលានីមួយៗ អ្នកស្រាវជ្រាវកំណត់យកតែនាយក/នាយិកានៅតាមសាលា បឋម និងអនុវិទ្យាល័យ ចំនួន១០២នាក់តែប៉ុណ្ណោះ។

វិធីសាស្រ្តស្រាវជ្រាវដើម្បីប្រមូលទិន្នន័យ គឺរៀបចំបែបគុណវិស័យ និងបរិមាណវិស័យ។ ក្នុងការស្រាវជ្រាវបែបបរិមាណវិស័យ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរពហុជ្រើសរើសសម្រាប់សួរ លោកនាយក/នាយិកា វិធីសាស្រ្តបែបគុណវិស័យអ្នកស្រាវជ្រាវចងក្រងជាសំណួរបើក ដើម្បីបន្ថែមទៅលើសំណួរបិទ សម្រាប់ឱ្យពួកគាត់ឆ្លើយតាមស្ថានភាពជាក់ស្តែងនៅតាមសាលានីមួយៗ។ ទិន្នន័យដែលប្រមូលបានអ្នកសិក្សាស្រាវជ្រាវវិភាគបែបគុណវិស័យ និងបរិមាណវិស័យ ហើយបានបញ្ចូលក្នុងកម្មវិធី (Excel) ដោយបង្កើតជាគំនូសតាង តារាង (Bar Graph) ជាក្រាហ្វិច និងភាគរយដើម្បីប្រៀបធៀបទាញសេចក្តីសន្និដ្ឋាន និងវាយតម្លៃលើលទ្ធផលដែលសម្រេចបាន។

តាមលទ្ធផលស្រាវជ្រាវ បង្ហាញថាសាលាបឋមសិក្សាទូទាំងខេត្ត តាមជាក់ស្តែង ខ្វះគ្រូចំនួន៧៦នាក់ ស្មើនឹង ១១% (៥៨២ ដក ៦៨៥) តាមនិយាមអប្បបរមា លើសគ្រូ១៨៣នាក់ ស្មើនឹង៤៥%

(៥៨២ ដក ៣៩៩) និងតាមនិយាមអតិបរមា លើសគ្រូ ២៦៨ ស្មើនឹង ៨៥% ធៀបនឹងថ្នាក់ជាក់ស្តែង និងគ្រូកំពុងបង្រៀនជាក់ស្តែង ។

សាលាអនុវិទ្យាល័យតាមនិយាមថ្មី (លេខ៖២០) លទ្ធផលបង្ហាញថា ខ្វះគ្រូ១៧នាក់ ស្មើនឹង ១០%។ គ្រូតាមមុខវិជ្ជាដែលខ្វះមាន១០មុខរួមមាន៖ ភាសាខ្មែរ ៥នាក់ ភាសាអង់គ្លេស៦នាក់ គណិតវិទ្យា ៩នាក់ ផែនដីវិទ្យា១នាក់ ភូមិវិទ្យា៦នាក់ សីលធម៌ ពលរដ្ឋ៤នាក់ កុំព្យូទ័រ៦នាក់ អប់រំសិល្បៈ៥នាក់ អប់រំសុខភាព៥នាក់ និងបំណិនជីវិតមូលដ្ឋាន៥នាក់។ ចំណែកឯមុខវិជ្ជាដែលលើសមានៈ រូបវិទ្យា៧នាក់ គីមីវិទ្យា១នាក់ ជីវវិទ្យា៩នាក់ ប្រវត្តិវិទ្យា៨នាក់ គេហវិទ្យា២នាក់ អប់រំកាយកីឡា៧នាក់ ។

សាលាអនុវិទ្យាល័យតាមនិយាមចាស់ (លេខ៖២៥៦) តាមជាក់ស្តែងលើសគ្រូ ៣៦នាក់ ស្មើនឹង ២២%។ គ្រូតាមមុខវិជ្ជាដែលលើសមាន៨មុខរួមមាន៖ ភាសាខ្មែរ៣នាក់ ភាសាអង់គ្លេស៥នាក់ រូបវិទ្យា៨នាក់ គីមីវិទ្យា២នាក់ ជីវវិទ្យា១០នាក់ ប្រវត្តិវិទ្យា១១នាក់ គេហវិទ្យា៣នាក់ អប់រំកាយ និងកីឡា៨នាក់។

សរុបមកយើងឃើញថាបំណែងចែកភារកិច្ចគ្រូបង្រៀននៅអនុវិទ្យាល័យ និងសាលាបឋមសិក្សាក្នុងខេត្តមណ្ឌលគិរីមិនទាន់មានលក្ខណៈត្រឹមត្រូវតាមនិយាមទាំងស្រុងនៅឡើយ ដោយកង្វះគ្រូបង្រៀនឯកទេសខ្លះៗ នៅតាមអនុវិទ្យាល័យមួយចំនួន ដែលធ្វើឱ្យគុណភាពអប់រំនៅមានកម្រិត។ ដូច្នេះក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាមន្ទីរអប់រំ និងភាគីពាក់ព័ន្ធនានាគួរពង្រាយគ្រូបង្រៀនពីសាលាលើសឱ្យទៅបម្រើការងារនៅសាលាខ្វះគ្រូ ជ្រើសរើសគ្រូថ្មីបន្ថែមទៀត ហើយបញ្ជូនទៅតាមតម្រូវការរបស់សាលាដែលបានស្នើសុំ ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមលើប្រាក់បៀវត្ស ឬផ្តល់លិខិតសរសើរ ចំពោះលោកគ្រូ អ្នកគ្រូដែលស្ម័គ្រចិត្តទៅបម្រើការនៅសាលាជនបទ ឬតំបន់ដាច់ស្រយាល ទប់ស្កាត់ការផ្ទេរគ្រូបង្រៀនចេញពីសាលាខ្វះគ្រូ ទៅសាលាខ្វះគ្រូ ដើម្បីពង្រឹងគុណភាពអប់រំនៅខេត្តមណ្ឌលគិរីឱ្យមានភាពល្អប្រសើរ។

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១.សេចក្តីផ្តើម

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បម្រើប្រទេសជាតិ មិនអាចកាត់ផ្តាច់ចេញ ពីការអប់រំបានឡើយ។ វិស័យអប់រំរីកចម្រើន និងមានប្រសិទ្ធភាពទាមទារជាចាំបាច់នូវកម្រិតសមត្ថភាពរបស់គ្រូបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងយកចិត្តទុកដាក់ថែរបំប៉នជាប្រចាំ។ ជាការពិតក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ វិស័យអប់រំក៏ដូចជាវិស័យផ្សេងទៀតដែរត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យ ទាំងធនធានមនុស្ស ទាំងមូលដ្ឋានសម្ភារបរិក្ខារ។ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើតឡើងវិញ សាលារៀនគ្រប់កម្រិតសិក្សាក្នុងទូទាំងប្រទេសត្រូវបានបើកទ្វារទទួលសិស្សានុសិស្ស (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, គោលនយោបាយស្តីពីគ្រូបង្រៀន, ២០១៥)។ ទន្ទឹមនឹងនេះការងារបណ្តុះបណ្តាល និងវិក្រិតការគ្រូបង្រៀនត្រូវបាន ចាប់ផ្តើមជាបន្ទាប់ ដោយមាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការជាអ្នកទទួលខុសត្រូវ។ ក្នុងស្ថានភាពដ៏លំបាកនេះ ការងារបណ្តុះបណ្តាល និងវិក្រិតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមពីការប្រមូលអតីតគ្រូបង្រៀន សិស្សនិស្សិត និងអ្នកមានកម្រិតវប្បធម៌មួយចំនួនដែលនៅសេសសល់ ពីការកាប់សម្លាប់មកបំប៉នចិត្តគរុកោសល្យ និងវិធីសាស្ត្របង្រៀនរយៈពេលខ្លី នៅតាមសាលាគរុកោសល្យ និងវិក្រិតការរាជធានី-ខេត្តទាំង១៨ រួចបញ្ជូនទៅកាន់សាលារៀនចំណោះទូទៅក្នុងទូទាំងប្រទេស ។ ជាមួយគ្នានេះដែរ ការបំប៉នមន្ត្រីគ្រប់គ្រងអប់រំក៏ត្រូវបានចាប់ផ្តើមផងដែរ តាមរយៈការបើកវគ្គបំប៉នប្រមូលផ្តុំនៅសាលាជាន់ខ្ពស់ កម្មាភិបាល គ្រប់គ្រងអប់រំដែល បច្ចុប្បន្នជាវិទ្យាស្ថានជាតិអប់រំ។ ចាប់ពីឆ្នាំ ១៩៨៣ ក្រសួងបានសម្រេចឱ្យសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្តទាំង១៨ និងសាលាមធ្យមសិក្សា គរុកោសល្យមត្តេយ្យមជ្ឈឹម បណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងមត្តេយ្យសិក្សារយៈពេលវែង ដោយចាប់ផ្តើមពីរូបមន្ត 7+1រហូតដល់ 12+2 សម្រាប់ខេត្តវាលរាប ។ ដោយឡែកសម្រាប់ខេត្តភូមិភាគឦសាន កោះកុង និងតំបន់ដាច់ស្រយាល

មួយចំនួន ការបណ្ដុះបណ្ដាលគ្រូបឋមសិក្សាត្រូវបានចាប់ផ្ដើមពីរូបមន្ត 3+1 និង បច្ចុប្បន្ន 9+2 និង 12+2 ។ នៅឆ្នាំ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៦ ត្រូវបានបង្កើតឡើងសម្រាប់បណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាបឋមសិក្សាភូមិដោយចាប់ផ្ដើមពីរូបមន្ត 7+3 រហូតបច្ចុប្បន្ន 12+2 (នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ, ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, ២០១០)។

ចាប់ពីឆ្នាំសិក្សា២០១៣-១៤ ក្រសួងអប់រំ យុវជន និងកីឡា មានបុគ្គលិកបង្រៀនសរុបស្មើនឹង ៨៣%ធៀបនឹងបុគ្គលិកទាំងអស់។ បច្ចុប្បន្នក្នុងចំណោមបុគ្គលិកបង្រៀនសរុប៨៨,៨១៨នាក់ គ្រូបង្រៀននៅសាលាបឋមសិក្សាមាន៥២% នៅមធ្យមសិក្សាបឋមភូមិមាន៣១% នៅមធ្យមសិក្សាទុតិយភូមិមាន ១២% និងនៅមត្តេយ្យសិក្សាមាន៥%។ បញ្ហាដែលគួរយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់គ្រូបង្រៀន គឺលំហូរចេញពីក្របខ័ណ្ឌគ្រូបង្រៀនដែលមាន២,០១៧នាក់ នៅឆ្នាំ២០១២ និង២,១៣៧នាក់នៅឆ្នាំ២០១៣។ ចំនួននេះមានទំហំធំ បើធៀបនឹងចំនួនក្របខ័ណ្ឌថ្មីដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវបណ្ដុះបណ្ដាលរៀងរាល់ឆ្នាំ ចំនួនប្រមាណ៥,០០០នាក់។ ការប្រើប្រាស់គ្រូបង្រៀនដែលរួមបញ្ចូលទាំងការពង្រាយ និងផលធៀបគ្រូ-សិស្សមិនទាន់បានអនុវត្តឱ្យបានត្រឹមត្រូវ តាមគោលការណ៍នៅឡើយទេ។ នោះគឺការអនុវត្តគោលនយោបាយ កំណែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា យុទ្ធសាស្ត្រទី៥៖ ធ្វើសនិទានកម្មគ្រូបង្រៀន ឱ្យឆ្លើយតបទៅនឹងតម្រូវការគ្រឹះស្ថានសិក្សា ត្រូវពិនិត្យឡើងវិញនូវការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយសនិទានកម្ម ក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការ អោយបានសមស្របតាមនិយាមកំណត់មួយ និងការពង្រាយអោយដល់ទីកន្លែងដែលមានតម្រូវការ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ និងសាលាគរុកោសល្យ (នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ, គោលនយោបាយស្ដីពីគ្រូបង្រៀន, ២០១៥) ។

បញ្ហាប្រឈមក្នុងការគ្រប់គ្រងគ្រូបង្រៀននៅកម្ពុជារួមមាន៖ ការកើនឡើងចំនួនកុមារដល់អាយុចូលរៀន ការពង្រីកសាលា ការជំនួសគ្រូចេញពីប្រព័ន្ធ ការជ្រើសរើសគ្រូដែលមានគុណវុឌ្ឍិ ការជ្រើសរើស និងបណ្ដុះបណ្ដាលគ្រូបង្រៀនការពង្រាយគ្រូបង្រៀន លក្ខខណ្ឌការងារ ការគ្រប់គ្រង ការឱ្យតម្លៃពី

សង្គម និងការលើកទឹកចិត្តជាពិសេសនៅសាលាជនបទដាច់ស្រយាល និងជួបការលំបាក។ ប្រសិនបើយើងពិនិត្យទៅលើសូចនាករ ផលធៀបសិស្សគ្រូ ឬសិស្សថ្នាក់ ហាក់បីដូចជាមិនមានបញ្ហានោះទេក្នុងក្របខ័ណ្ឌទូទាំងប្រទេស ព្រោះតាមស្ថិតិនៅគ្រប់កម្រិត ភូមិសិក្សាមានសិស្ស និស្សិតប្រមាណ៣លានប្រាំសែននាក់ រីឯបុគ្គលិកបង្រៀនមានជាងដប់ម៉ឺននាក់ (ក្រសួងអប់រំយុវជននិងកីឡា, ២០១៨)។

**តើបញ្ហាទាំងអស់នេះបណ្តាលមកពីមូលហេតុអ្វី**?

ដូច្នេះហើយបានជានាងខ្ញុំ ជ្រើសរើសប្រធានបទ "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី**" នេះមកសិក្សាស្រាវជ្រាវដើម្បីស្វែងរកឱ្យឃើញ នូវមូលហេតុពិតប្រាកដ ក្នុងគោលបំណងកែលម្អ និងបំពេញភាពខ្វះចន្លោះ ទៅលើការប្រើប្រាស់គ្រូបង្រៀន អោយមានប្រសិទ្ធភាពក្នុងវិស័យអប់រំនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។

## ១.២.លំនាំបញ្ហានៃការស្រាវជ្រាវ

ទោះបីជាមានសេចក្តីណែនាំ ក៏ដូចជាសារាចរណ៍ផ្សេងៗ បានផ្តល់ជូនសម្រាប់ធ្វើការអនុវត្តទៅតាមកម្រិតមន្ទីរ ឬកម្រិតសាលាយ៉ាងណាក៏ដោយ ក៏ការបែងចែងគ្រូនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនានានៅក្នុងខេត្តមណ្ឌលគិរី នៅមានភាពមិនប្រក្រតីមួយចំនួន ដែលក្នុងនោះមានកត្តាមួយចំនួនដែលកំពុងជួបប្រទះ ដូចជាគ្រូបង្រៀនខុសឯកទេស គ្រូបង្រៀនមិនគ្រប់ម៉ោងតាមនិយាម កំណត់គ្រូបង្រៀនលើសនៅសាលាទីប្រជុំជន ខ្វះគ្រូបង្រៀននៅសាលារៀនជនបទ និងសាលារៀនតំបន់ដាច់ស្រយាល ចំណែកឯការបែងចែកសិស្ស ថ្នាក់វិញ មិនស្របទៅតាមនិយាមដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា កត្តាទាំងអស់នេះហើយដែលតម្រូវឱ្យភាគីពាក់ព័ន្ធគួរតែមានវិធានការមួយចំនួនសម្រាប់ធ្វើការកែលម្អ និងពង្រឹងបន្ថែមដើម្បីគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ។

## ១.៣ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីចូលរួមចំណែកកែលម្អគុណភាពអប់រំនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង ក្នុងនាមខ្ញុំជាគរុនិស្សិតឯកទេសៈ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ បានយក

ប្រធានបទស្តីពី "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សានិងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី**" ដើម្បីស្វែងរកឱ្យឃើញពីការបែងចែកភាកិច្ចគ្រូបង្រៀន និងម៉ោងបង្រៀនរបស់គ្រូម្នាក់ៗត្រឹមត្រូវតាមឯកទេស និងស្របតាមនិយាមគរុកោសល្យរបស់ក្រសួងអប់រំ យុវជន និងកីឡា។ម្យ៉ាងទៀតការសិក្សាស្រាវជ្រាវនេះចង់ស្វែងរកឱ្យឃើញបន្ថែមទៀត នូវបញ្ហាប្រឈមជាក់ស្តែងដែលកំពុងកើតមានឡើងនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យទាំង១០២ក្នុងខេត្តមណ្ឌលគិរី។

## ១.៤. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានវត្ថុបំណង៖

១. ដើម្បីរកឱ្យឃើញការបែងចែក និងការប្រើប្រាស់គ្រូនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌល គិរីនាពេលបច្ចុប្បន្នសមស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

២. កាត់បន្ថយការប្រើប្រាស់គ្រូខុសពីតម្រូវការជាក់ស្តែង និងខុសមុខវិជ្ជាឯកទេស ជាហេតុធ្វើឱ្យការអប់រំនៅតាមសាលាថយចុះ។

៣. ឈ្វេងយល់ពីទស្សនៈយល់ឃើញរបស់នាយក/នាយិកា លើការដោះស្រាយបញ្ហានានាទាក់ ទងទៅនឹងការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី។

## ១.៥. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបគោលបំណងស្រាវជ្រាវខាងលើ ការសិក្សាស្រាវជ្រាវនេះត្រូវបានយកសំណួរពីរស្រាប់ធ្វើការសិក្សាស្រាវជ្រាវ៖

១. តើការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី មានស្ថានភាពបែបណាខ្លះ?

២. តើនាយក/នាយិកាមានទស្សនៈយល់ឃើញបែបណាខ្លះលើការដោះស្រាយបញ្ហានានាទាក់ទងនឹងការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យនានាក្នុងខេត្តមណ្ឌលគិរី?

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះជាការចូលរួមចំណែកមួយផ្នែករបស់ ក្រសួងអប់រំ ដើម្បីធ្វើជាដំណោះស្រាយក្នុងការបែងចែក និងការប្រើប្រាស់គ្រូឱ្យមានប្រសិទ្ធភាព ចំពោះការជ្រើសរើសចំនួនគ្រូ ក្នុងការបណ្តុះបណ្តាលឱ្យត្រូវតាមតម្រូវការជាក់ស្តែង ក៏ដូចជាព័ត៌មានមួយជួយផ្តល់ដល់ខាងមន្ទីរ ក្នុងការបែងចែកនិងប្រើប្រាស់គ្រូឱ្យត្រូវតាមតម្រូវការរបស់ការិយាល័យក្រុង/ស្រុកនីមួយៗ ងាយស្រួលបញ្ជូនគ្រូដែលបណ្តុះបណ្តាលរួច ឱ្យទៅដល់សាលារៀនដែលនាយក/នាយិកាបានស្នើសុំ។

## ១.៧. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៧.១.វិសាលភាពនៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវដំណើរការបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើប្រធានបទស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី អ្នកស្រាវជ្រាវបានយកសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរីទាំងអស់តែប៉ុណ្ណោះដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

### ១.៧.២.ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះ ផ្តោតទៅលើតែស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនដែលមានក្របខ័ណ្ឌគរុកោសល្យនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅក្នុងខេត្តមណ្ឌលគិរី ចំនួន១០២សាលា (ក្រុងចំនួន១ និងស្រុកចំនួន៤) អ្នកស្រាវជ្រាវបានផ្តល់ជាកម្រងសំណួរបែបគុណវិស័យ និងបរិមាណវិស័យ សម្រាប់សម្ភាសន៍ នាយក/នាយិកាសាលាទាំងអស់ ចំនួន១០២នាក់ក្នុងខេត្ត។ នាយក/នាយិកាសាលាបឋមសិក្សាចំនួន៨៨នាក់ និងអនុវិទ្យាល័យចំនួន១៤នាក់ កម្រងសំណួរបានផ្តោតទៅលើ២ចំណុច៖ ១. ការកំណត់តម្រូវការ ២. ទស្សនៈរបស់នាយកសាលាលើបញ្ហាប្រឈមលើស និងខ្វះគ្រូបង្រៀន ដើម្បីប្រមូលទិន្នន័យសម្រាប់ធ្វើការសរសេរនិក្ខេបបទ គ្មានបំណងអ្វីផ្សេងក្រៅពីនេះឡើយ។

តារាងទី១ ៖ ចំនួនសាលាបឋមសិក្សានិងអនុវិទ្យាល័យទូទាំងខេត្តមណ្ឌលគិរី

| ល.រ | ក្រុង/ស្រុក | ចំនួនសាលា | |
|---|---|---|---|
| | | បឋមសិក្សា | អនុវិទ្យាល័យ |
| ១ | សែនមនោរម្យ | ០៩ | ០២ |
| ២ | អូររាំង | ១០ | ០២ |
| ៣ | កោះញែក | ២៤ | ០២ |
| ៤ | ពេជ្រាដា | ១៨ | ០៣ |
| ៥ | កែវសីមា | ២៧ | ០៥ |
| សរុប | | ៨៨ | ១៤ |

## ១.៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានលទ្ធផលល្អ អ្នកស្រាវជ្រាវបានរៀបចំរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះដោយបែងចែកជា ៥ជំពូកដូចខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើម** ជំពូកនេះបានបង្ហាញពីដំណាក់កាល នៃការបណ្តុះបណ្តាលគ្រូតាមគរុកោសល្យ និងការបែងចែកគ្រូទៅតាមតំបន់ផ្សេងៗទូទាំងប្រទេស មិនបានសមស្របទៅតាមតម្រូវការនៅណាតាមតំបន់ ជាមូលហេតុដែលធ្វើឱ្យមានការស្រាវជ្រាវក្នុងគោលបំណងជាការរួមចំណែក ក្នុងការដោះស្រាយការបែងចែក និងប្រើប្រាស់គ្រូនៅសាលាបឋម និងអនុវិទ្យាល័យ ក្នុងខេត្តមណ្ឌលគិរី ដើម្បីឱ្យសមស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ។

**ជំពូកទី២៖ រំឭកទ្រឹស្តី** នៅក្នុងជំពូកនេះបង្ហាញពី ដំណើរការនៃការបំពេញតួនាទីភារកិច្ច របស់បុគ្គលិកអប់រំ ទៅតាមសេចក្តីណែនាំលេខ៖ ២៥៦ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជកា, លេខ៖ ២០ស្តីពីការនិយាមប្រើបុគ្គលិកអប់រំ, លេខ៖៥៣ ស្តីពីការគ្រប់គ្រងគ្រូបង្រៀន , លេខ៖២៨ ស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិក ដើម្បីជាជំនួយក្នុងការស្រាវជ្រាវ។

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** បង្ហាញពីដំណើរការនៃការស្រាវជ្រាវ ទាក់ទងទៅនឹងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យស្ថិតិ គ្រូ សិស្ស ថ្នាក់ នៅតាមសាលាទូទាំងខេត្ត តាមរយៈកម្រងសំណួរសម្ភាសន៍ផ្ទាល់ និងតាមប្រព័ន្ធបច្ចេកវិទ្យា (google forms) មកវិភាគទៅលើទិន្នន័យដែលប្រមូលបានតាមកម្មវិធី Excel បង្កើតជាតារាង និង ក្រាហ្វិច ដោយធ្វើការវិភាគលទ្ធផលតាមបែបបរិមាណវិស័យ និងគុណវិស័យ ដោយស្តែងចេញពីក្រមសីលធម៌របស់អ្នកស្រាវជ្រាវក្នុងការសរសេរនិក្ខេបបទ។

**ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ** បង្ហាញពីលទ្ធផលស្រាវជ្រាវ ដែលបានរកឃើញពីស្ថានភាពនៃការប្រើប្រាស់គ្រូបឋមសិក្សា និងអនុវិទ្យាល័យ តាមជាក់ស្តែង ធៀបនឹងនិយាម គ្រូ សិស្ស ថ្នាក់ និង គ្រូតាមមុខវិជ្ជាឯកទេសដោយបង្ហាញតាមរយៈ តារាង និងក្រាហ្វិច រួចធ្វើការបកស្រាយតាមលទ្ធផលជាក់ស្តែង ករណីលើស និងខ្វះគ្រូតាមសាលានីមួយៗ ក្នុងក្រុង/ស្រុក និងទស្សនៈរបស់នាយក/នាយិកាសាលា ទៅដំណោះស្រាយលើបញ្ហាប្រឈម លើស និងខ្វះគ្រូ ការស្នើសុំគ្រូក្របខ័ណ្ឌបន្ថែម និងសំណូមពរទៅកាន់រដ្ឋបាលថ្នាក់លើ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ជាការសន្និដ្ឋានរួមលើលទ្ធផលចម្លើយ ទៅនឹងកម្រងសំណួរស្រាវជ្រាវខាងលើ នៃប្រធានបទស្តី ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនសាលាបឋមសិក្សា និងអនុវិទ្យាល័យ និងសំណូមពរទៅកាន់ក្រសួងអប់រំ មន្ទីរ ការិយាល័យក្រុង/ស្រុក និងលោកនាយក/នាយិកាសាលា។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១. សេចក្តីផ្តើម

ការបែងចែកធនធានអប់រំនៅក្នុងប្រទេសកម្ពុជា មានការផ្លាស់ប្តូរទៅតាមបរិបទនៃប្រទេស និងតាមដំណាក់កាលនីមួយៗ។ ពីឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២០ ការបែងចែកធនធានអប់រំគឺ គ្រូម្នាក់បង្រៀនសិស្ស១ថ្នាក់ ហើយសិស្សមួយថ្នាក់មានចន្លោះពី៤០ ទៅ ៥០នាក់ សិស្សរៀន ២៥ ម៉ោងក្នុងមួយសប្តាហ៍ចំពោះបឋមសិក្សា ផ្នែកអនុវិទ្យាល័យវិញគ្រូបង្រៀនសុទ្ធសាធ១៨ ម៉ោងក្នុងមួយសប្តាហ៍ បើទទួលបន្ទុកថ្នាក់ផងបង្រៀនតែ១៤ ម៉ោងក្នុងមួយសប្តាហ៍ បើគ្រូទទួលបន្ទុកថ្នាក់ហើយជាប្រធានក្រុមបច្ចេកទេសទៀតគាត់បង្រៀនតែ១២ម៉ោងក្នុងមួយសប្តាហ៍។ (សេចក្តីណែនាំលេខ២០អយក.សណន, ២០១៨)។

ចាប់តាំងពីឆ្នាំ២០០២ រហូតមកដល់ឆ្នាំ ២០១៧ ការបែងចែកធនធានអប់រំគឺ គ្រូម្នាក់បង្រៀនសិស្ស ១ថ្នាក់ដែលមានសិស្សចំនួន ៥០នាក់ ផ្នែកបឋមសិក្សា ឯផ្នែកអនុវិទ្យាល័យ សិស្សមួយថ្នាក់មានចំនួន ៥០នាក់ គ្រូម្នាក់បង្រៀន១៨ម៉ោងក្នុងមួយសប្តាហ៍ បើទទួលបន្ទុកថ្នាក់បង្រៀនតែ១៥ ម៉ោងក្នុងមួយសប្តាហ៍ ករណីបង្រៀនមិនគ្រប់ម៉ោងកំណត់ខាងលើក្នុងមុខវិជ្ជាណាមួយ មន្ត្រីអប់រំនោះត្រូវបង្រៀនមុខវិជ្ជាផ្សេង ឬត្រូវបង្រៀនភូមិសិក្សាខ្ពស់ជាង ឬទាបជាងឱ្យគ្រប់ម៉ោងកំណត់និងអាចបង្រៀនម៉ោងបន្ថែមបានលុះត្រាតែមន្ត្រីអប់រំនោះបានបង្រៀនគ្រប់ម៉ោងកំណត់របស់ក្របខ័ណ្ឌខ្លួនសិន (សេចក្តីណែនាំលេខ២៥៦អយក.សណន, ២០០២) ។

ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០១ គ្រូបង្រៀនដែលទទួលបានការ បណ្តុះបណ្តាលគរុកោសល្យហើយត្រូវបានបញ្ជូនកាន់សាលាដែលខ្វះគ្រូខ្លាំងដោយគ្រូបង្រៀនម្នាក់អាចបង្រៀនពីរមុខ ទៅបីមុខវិជ្ជា ដែលធ្វើឱ្យលទ្ធផលនៃការសិក្សារបស់សិស្សនៅមានកម្រិត ចំពោះសាលាបឋមសិក្សាវិញបង្កើតឱ្យមានថ្នាក់គួបថ្នាក់ពីរវេនដោយសារតែខ្វះគ្រូបង្រៀន។ ពីឆ្នាំ ១៩៨៦ មកដល់ឆ្នាំ ១៩៩៥ ប្រព័ន្ធអប់រំ ៥-៣-៣ ចំនួនឆ្នាំសិក្សា១១ឆ្នាំចាប់ផ្តើមមានការបង្កើតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដើម្បីបណ្តុះបណ្តាលគ្រូបឋមសិក្សា

ទៅជាគ្រូមធ្យមសិក្សា បឋមភូមិតាមរូមន្ត៧+១សម្រាប់ខេត្តតំបន់វាលរាបនិង៣+១ សម្រាប់ខេត្តជួបការលំបាក និងតំបន់ដាច់ស្រយាល ដោយគ្រូម្នាក់បង្រៀន ១៨ម៉ោងក្នុង ១សប្តាហ៍ហើយវិធីសាស្ត្របង្រៀនតាមបែបគ្រូមជ្ឈមណ្ឌល។ បើគ្រូបង្រៀនលើសនិយាមកំណត់ ត្រូវគិតប្រាក់ម៉ោងបន្ថែមជូនគាត់។ ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៥ ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា ៤-៣-៣ ចំនួនឆ្នាំសិក្សា១០ឆ្នាំមានតែគ្រូកម្រិតបឋមសិក្សា ក្នុងដំណាក់កាលនេះ ក្រសួងជ្រើសរើសយកអ្នកស្ម័គ្រចិត្ត ដើម្បីឱក្លាយជាគ្រូបង្រៀនដោយបណ្តុះបណ្តាលពួកគាត់មួយសប្តាហ៍ ទៅបួនខែប៉ុណ្ណោះ ដោយបញ្ជូនគាត់ទៅបង្រៀនសិស្សក្នុងមួយថ្នាក់ៗរាប់សិបនាក់ដោយមិន បានកំណត់តាមនិយាមច្បាស់លាស់ឡើយ (ក្រសួងអប់រំ យុវជន និងកីឡា, 1998)។

## ២.២. ភារកិច្ចត្រូវបំពេញ និងតួនាទីរបស់ខ្លួន

ការបំពេញការងារ ឬតួនាទីត្រូវធ្វើដោយសាមីអ្នករាជការផ្ទាល់ខ្លួន មិនត្រូវផ្ទេរទៅឱ្យអ្នកដទៃជំនួសឡើយ លើកលែងតែមានការកំណត់ផ្សេងៗ ដោយច្បាប់ក្នុងករណីខ្លះតែប៉ុណ្ណោះ ព្រោះថាការចូលបម្រើក្នុងក្របខ័ណ្ឌ ធ្វើឡើងតាមរយៈការប្រឡងប្រជែងជ្រើសរើសតាមកម្រិតវប្បធម៌ តាមសមត្ថភាពផ្ទាល់របស់សាមីជន។ ការទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួន និងសមត្ថភាពវិជ្ជាជីវៈ ឬប្រសិទ្ធភាពការងារគឺជាកាតព្វកិច្ចដ៏សំខាន់ដែលអ្នករាជការសារជារណៈរាល់រូបត្រូវបំពេញឱ្យបាន និងដុះខាត់គំនិតច្នៃប្រឌិតឱ្យបានជាប្រចាំ។ ការសិក្សាអប់រំជាប្រចាំអាចធ្វើឱ្យអ្នកអនុវត្តការងារតាមទាន់សភាពការណ៍ ហើយគ្រប់គ្រងបាននូវស្ថានការប្រែប្រួល ផ្លាស់ប្តូរ ឬវិវត្តន៍បានយ៉ាងងាយស្រួល។

## ២.៣. សារៈសំខាន់នៃការគ្រប់គ្រង និងដឹកនាំអង្គភាព

ការងារគ្រប់គ្រងអាចកំណត់ថាជាការដាក់ចេញនូវគោលដៅរួមរបស់អង្គភាព ឬស្ថាប័ន ហើយបន្ទាប់មកធ្វើការសម្រេចថាតើត្រូវប្រើប្រាស់បុគ្គលិក និងធនធានយ៉ាងដូចម្តេចដើម្បីឈានទៅសម្រេចគោលដៅនេះ។ ចំណុចនេះមិនត្រឹមតែទាមទារនូវជំនាញសំខាន់ខាងលើទេ ថែមទាំងទាមទារនូវជំនាញសំខាន់ៗផ្សេងៗទៀតដូចជាសមត្ថភាពទំនាក់ទំនងល្អ ការយល់ និងការដោះស្រាយបញ្ហា ការដឹងថាតើត្រូវប្រើ

ប្រាស់ធនធានដូចម្តេច ដើម្បីឱ្យមានប្រសិទ្ធភាពបំផុត (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ការងារគ្រប់គ្រង រដ្ឋបាល, ២០០៦)។

ដោយហេតុនេះដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀន នៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនខ្ចីឆ្លងភូមិសិក្សា ចាប់ពីឆ្នាំសិក្សា ២០១៩ - ២០២០ ក្រសួង អប់រំ យុវជន និងកីឡា ដាក់ចេញនូវវិធានការដូចខាងក្រោម៖

### ២.៣.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ

គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាង ឬស្មើ៣ថ្នាក់និងចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន។ (១) មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យ និងរៀបចំស្វ័យប្រកាសសាលារៀន ដែលមានតម្រូវការស្រូបង្រៀនតាមប្រភេទក្របខ័ណ្ឌ និងមុខវិជ្ជាជំនាញនឹងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខ័ណ្ឌ ឱ្យទៅដល់សាលារៀន ដែលកំពុងខ្វះគ្រូបង្រៀន (២) គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខ័ណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅ ដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ (៣) ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងរាជធានី ខេត្ត (៤) ចុះពិនិត្យការអនុវត្តនិយាម (ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន) (៥) ក្រសួងនឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្តល់ក្របខ័ណ្ឌបណ្តោះអាសន្ន (៦) ក្រសួងនឹងពិនិត្យស្នើគោលការណ៍ ផ្តល់បៀវត្សមូលដ្ឋានដល់គរុសិស្ស គរុនិស្សិត បន្ទាប់ពីបានប្រឡងជាប់ (សេចក្តីណែនាំលេខ៥៣អយក.សណន, ២០១៩)។

### ២.៣.២. ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា

គ្រឹះស្ថានសិក្សានីមួយៗ ត្រូវធ្វើការវិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខ័ណ្ឌ និងមុខវិជ្ជាជំនាញឱ្យបានច្បាស់លាស់មុននឹង លើកសំណើសុំគ្រូបង្រៀនបន្ថែមរួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនពីរថ្នាក់ពីរពេល ។ល។

ការវិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្សត្រូវអនុលោមតាម សេចក្តីណែនាំលេខ៖២០ អយក.សណន ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំលេខ៤៩៨ មស.សណន ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេនគ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅតាមគ្រឹះស្ថាន បឋមសិក្សាសាធារណៈ របស់ក្រសួងមុខងារសាធារណៈ។ គ្រឹះស្ថានសិក្សានីមួយៗ ត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិក/គ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញ មិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងពេលអនាគត។ គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីធានាថា បុគ្គលិក/គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមក នឹងបំពេញនូវតម្រូវការធនធានមនុស្ស សម្រាប់ពេលបច្ចុប្បន្ន និងមិននៅសល់ក្នុងពេលអនាគត។

### ២.៣.៣. ការរៀបចំផែនការក្របខ័ណ្ឌប្រចាំឆ្នាំ

អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិត្រូវសហការណ៍គ្នា ដើម្បីរៀបចំផែនការមេស្តីពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនដោយ ផ្អែកលើចំណោលសិស្ស។ ប្រមូលផ្តុំទិន្នន័យគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀន ចូលនិវត្តន៍ គ្រូបង្រៀនផ្លាស់ចេញពីក្របខ័ណ្ឌ និងមរណជន។ រៀបចំសំណើសុំក្របខ័ណ្ឌថ្មី គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរវេន ដើម្បីដាក់ជូន ក្រសួងមុខងារសាធារណៈ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តដូចគ្នានឹងចំណុចខាងលើ ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា (សេចក្តីណែនាំលេខ៥៣អយក.សណន, ២០១៩)។

### ២.៣.៤. ការជ្រើសរើសបុគ្គលិកចូលក្របខ័ណ្ឌ

(១) បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌ (២) បន្តប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មី ទៅតាមប្រភេទក្របខ័ណ្ឌ មុខវិជ្ជាជំនាញ (៣) ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្ត ដាច់ ស្រយាល (៤) បន្តប្រឡងជ្រើសរើសបញ្ចូលក្របខ័ណ្ឌចំពោះបេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត (៥) ការជ្រើសរើសគ្រូបន្ថែម គួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ចប់ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំង កាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន (៦) ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់ (៧) ការប្រឡងជ្រើសរើសគ្រូក្របខ័ណ្ឌថ្មីគួរពិនិត្យជម្រើសប្រឡងជ្រើសរើសក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះ ដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ (៨) ការបែងចែកក្របខ័ណ្ឌថ្មី សម្រាប់ការប្រឡងជ្រើសរើស ត្រូវរៀបចំតាមដំណាក់កាល៖ បន្ទាប់ពីទទួលបានតួលេខសម្រាប់ការប្រឡងជ្រើសរើសក្របខ័ណ្ឌប្រចាំឆ្នាំក្រសួង ត្រូវប្រជុំពិនិត្យ ការបែងចែកតួលេខដាក់ញប់ឱ្យទៅដល់រាជធានី ខេត្តនីមួយៗ ទាំងគ្រូបង្រៀនកម្រិតឧត្តម កម្រិត មូលដ្ឋាន និងបឋម-មត្តេយ្យសិក្សា ដោយផ្អែកលើស្ថានភាពខ្វះជាក់ស្តែង បន្ទាប់ពីទទួលបានតួលេខរួចហើយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តនីមួយៗ ត្រូវយកទៅបែងចែកឱ្យទៅដល់សាលារៀន ដែលកំពុងខ្វះជាក់ស្តែងតាមប្រភេទក្របខ័ណ្ឌ និងតាមមុខវិជ្ជាជំនាញ ចំពោះគ្រូបង្រៀនកម្រិតមូលដ្ឋាន និងកម្រិតឧត្តម ដោយបញ្ជាក់ឈ្មោះសាលារៀនដែលមានតម្រូវ ការឱ្យបានច្បាស់ លាស់ និងលើកសំណើមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបុគ្គលិក ដើម្បីសុំការសម្រេច បន្ទាប់ពីទទួលបានសំណើ ស្តីពីតម្រូវការគ្រូបង្រៀនរបស់រាជធានី ខេត្ត ក្រសួងត្រូវរៀបចំប្រជុំលើកទី២ ដើម្បីពិនិត្យនិងសម្រេច ហើយបញ្ជូនត្រឡប់ទៅវិញដើម្បីអនុវត្តសម្រាប់ការប្រឡងជ្រើសរើស (សេចក្តីណែនាំលេខ៥៣អយក.សណន, ២០១៩)។

## ២.៣.៥. ដំណោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន

ពង្រឹងការអនុវត្តសេចក្ដីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្ដីពីការបែង ចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួន ដូចខាងក្រោម) (១) ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី ខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍ (២) គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើស ត្រូវទៅបម្រើការនៅទីនោះ (ក) បញ្ឈប់ការប្ដូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច (ខ) គ្រូបង្រៀនចេញថ្មីដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្ស ឬស្នើលុបឈ្មោះចេញពីក្របខ័ណ្ឌភ្លាម។

### ២.៣.៥.១ សាលារៀនលើសគ្រូបង្រៀន

*ករណីរាជធានីភ្នំពេញ*

អនុវត្តសាកល្បងនៅរាជធានីភ្នំពេញដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀន ដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។

*ករណីខេត្តផ្សេងទៀត*

បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន ដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ សុំគោលការណ៍ផ្ដល់ប្រាក់បំណាច់មុខងារពិសេស ដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការ លំបាកខ្លាំង។

### ២.៣.៥.២ សាលារៀនខ្វះគ្រូបង្រៀន

(១) ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្ដល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ (២) ពិភាក្សាជាមួយ

ក្រសួងពាក់ព័ន្ធដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់ សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ការស្នើបញ្ចូលក្របខ័ណ្ឌ (ទាំងគ្រូក្របខ័ណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព (សេចក្តីណែនាំលេខ៥៣អយក.សណន, ២០១៩)។

### ២.៣.៥.៣ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

(១)ធ្វើទំនើបកម្មផែនការតម្រូវកា រនិងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ ការបណ្តុះបណ្តាលមុនពេលបម្រើការងារ (២) ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់ និងតាមគោលការណ៍ (៣) លើកកម្ពស់ការគ្រប់គ្រងនិងរៀបចំក្របខ័ណ្ឌគ្របង្រៀន (៤) លើកកម្ពស់ដំណើរការ និងនីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អសម្រាប់ជានានិរន្តរភាពគ្រឹះស្ថានសិក្សា(៥) ធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់ (៦) លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធិ សិក្សារបស់សិស្ស។

### ២.៣.៥.៤ ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

(១) លើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្តល់បៀវត្សរលាភការសុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក (២) ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ (៣) លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។

### ២.៣.៥.៥ ពង្រឹងប្រសិទ្ធភាព ជាអ្នកដឹកនាំសាលា

(១) ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព (២) ធានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ (៣) ធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើសបណ្តុះបណ្តាលបំពេញការងារ និងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេសនិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ(៤) កំណត់និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃគ្រឹះស្ថានសិក្សាសាធារណៈ សំដៅធានាការអនុវត្តគោលការណ៍និងបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ (សេចក្តីណែនាំលេខ៥៣អយក.សណន, ២០១៩)។

## ២.៤. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា និងម៉ោងបំពេញការងារបុគ្គលិកអប់រំ

### ២.៤.១. ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា

តារាងទី២៖ ប្រភេទគ្រឹះស្ថានសិក្សា

| គ្រឹះស្ថានសិក្សា | សាលាតូច | សាលាមធ្យម | សាលាធំ |
|---|---|---|---|
| មត្តេយ្យសិក្សា | តិចជាងឬស្មើ ៣ ថ្នាក់ | ចាប់ពី ៤ ដល់ ៦ ថ្នាក់ | ចាប់ពី ៧ ឡើងទៅ |
| បឋមសិក្សា | តិចជាងឬស្មើ ២០ ថ្នាក់ | ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | ចាប់ពី ៤១ ឡើងទៅ |
| មធ្យមសិក្សា | តិចជាងឬស្មើ ២០ ថ្នាក់ | ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | ចាប់ពី៤១ ឡើងទៅ |

### ២.៤.២. ការកំណត់ម៉ោងបំពេញការងារបុគ្គលិកអប់រំ

តារាងទី៣៖ ម៉ោងបំពេញការងារបុគ្គលិកអប់រំ

| ប្រភទគ្រឹះស្ថានសិក្សាសាធារណៈ | ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ ក្នុង១សប្តាហ៍ | ចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀនក្នុង១សប្តាហ៍ |
|---|---|---|
| មត្តេយ្យសិក្សា | ១៨ ម៉ោង | ៧ ម៉ោង |

| សាលារៀនចំណេះទូទៅ | | |
|---|---|---|
| បឋមសិក្សា | ២៥ ម៉ោង | ៥ ម៉ោង |
| មធ្យមសិក្សាបឋមភូមិ | ១៨ ម៉ោង | ២២ ម៉ោង |
| មធ្យមសិក្សាទុតិយភូមិ | ១៦ ម៉ោង | ២៤ ម៉ោង |
| **គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន** | | |
| សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម<br>វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា<br>សាលាគរុកោសល្យ និងវិក្រឹតការខេត្ត<br>មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ១៤ ម៉ោង | ២៦ ម៉ោង |
| វិទ្យាស្ថានគរុកោសល្យ<br>វិទ្យាស្ថានជាតិអប់រំពិសេស<br>វិទ្យាស្ថានជាតិអប់រំ | ១២ ម៉ោង | ២៨ ម៉ោង |
| **ឧត្តមសិក្សា** | | |
| ថ្នាក់បរិញ្ញាបត្រ | ១២ ម៉ោង | ២៨ ម៉ោង |
| ថ្នាក់ក្រោយឧត្តមសិក្សា | ១០ ម៉ោង | ៣០ ម៉ោង |
| បុគ្គលិកនៅមន្ទីរពិសោធន៍ បន្ទប់កុំព្យូទ័រ រោងជាង | | ៤០ ម៉ោង |
| បរិវច្ឆការី គ្រូអនុវត្តនៅមន្ទីរពិសោធន៍ និងគ្រូនៅរោងជាងសិក្សា | | ៤០ ម៉ោង |

**សម្គាល់៖**

ម៉ោងគាំទ្រលើការបង្រៀនត្រូវគោរពតាមការចាត់តាំងឱ្យបានសមស្រប និងចាំបាច់របស់អង្គភាព និងចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀន រួមមានការណែនាំអនុវត្ត ជួយបង្រៀនបន្ថែមសិស្សរៀន យឺត រៀបចំកិច្ចតែងការបង្រៀន កែកិច្ចការសិស្ស ជួបមាតាបិតាសិស្ស ការស្រាវជ្រាវ។ល។ ចំពោះផ្នែក

ជំនាញដូចជាៈ ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ គឺអនុវត្តដូចមធ្យមសិក្សាទុតិយភូមិ ថ្នាក់មធ្យមសិក្សាបច្ចេកទេស អនុវត្ត ដូចសាលាគរុកោសល្យខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ ក្នុងករណីបរិវច្ឆការី ជាគ្រូដែលមានក្របខ័ណ្ឌជាគ្រូបង្រៀនកម្រិតបឋម គ្រូបង្រៀនកម្រិតមូលដ្ឋាន គ្រូបង្រៀនកម្រិតឧត្តម ម៉ោងកំណត់ត្រូវអនុវត្តតាមប្រភេទក្របខ័ណ្ឌនីមួយៗ។ (សេចក្តីណែនាំលេខ២០អយក.សណន, ២០១៨)

## ២.៥ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀន

យោងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា សារាចរណ៍ណែនាំលេខៈ០១សរណន ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការអនុវត្តផែនការក្រខណ្ឌប្រចាំឆ្នាំ។ ដើម្បីអនុវត្តឱ្យបានសម្រេចនូវយុទ្ធសាស្ត្រកំណែទម្រង់ការងារគ្រប់គ្រងបុគ្គលិកវិស័យអប់រំយុវជន និងកីឡាលើការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកឱ្យទទួលបានប្រសិទ្ធភាពព្រមទាំងឆ្លើយតបនិងតម្រូវការប្រើប្រាស់បុគ្គលិកអប់រំនៅតាមអង្គភាព និងគ្រឹះស្ថាននានា ក្រសួងសូមធ្វើការណែនាំដូចខាងក្រោមៈ

### ២.៥.១ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកក្នុងរាជធានី/ខេត្ត

បុគ្គលិកអប់រំបានបម្រើការងារក្នុងរាជធានី/ខេត្តយ៉ាងតិចរយៈពេល០៣ឆ្នាំ មានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងធ្វើការងារទៅកាន់អង្គភាពនឹងគ្រឹះស្ថានសិក្សាដែលកំពុងខ្វះបុគ្គលិកអប់រំ។ បុគ្គលិកអប់រំដែលជាប់កិច្ចសន្យានៅតំបន់ជួបការលំបាកត្រូវបម្រើការងាររហូតដល់ចប់កិច្ចសន្យារយៈពេល០៥ឆ្នាំ ទើបមានសិទ្ធដាក់ពាក្យប្តូរទីកន្លែងបម្រើការងាររបស់ខ្លួនបាន។ ចំពោះអង្គភាព ឬគ្រឹះស្ថានសិក្សាមានបុគ្គលិកអប់រំដែលដាក់ពាក្យសុំទំនេរគ្មានប្រាក់បៀវត្ស សុំផ្ទេរក្របខ័ណ្ឌចេញក្រៅក្រសួង និងបុគ្គលិកលើសតម្រូវការឬដោះស្រាយការសិក្សារបស់សិស្សមិនអនុញ្ញាតផ្លាស់ចូលឡើយ។ មន្ទីរអប់រំយុវជន និងកីឡារាជធានី/ខេត្ត ត្រូវរៀបចំសេចក្តីសម្រេចលទ្ធផល នៃការផ្លាស់ប្តូរទីកន្លែងបម្រើការងារ រាជធានី/ខេត្តឱ្យចប់ត្រឹមសប្តាហ៍ទី៣ ក្នុងខែកញ្ញារួចផ្ញើលទ្ធផលមកក្រសួង (នាយកដ្ឋានបុគ្គលិក) ឱ្យបានមុនដំណាច់សប្តាហ៍ទី៤ ក្នុងខែកញ្ញាដដែល។

## ២.៥.២ ការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកឆ្លងរាជធានី/ខេត្ត

បុគ្គលិកអប់រំបានបម្រើការងារក្នុងរាជធានី/ខេត្តយ៉ាងតិចរយៈពេល០៤ឆ្នាំ មានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងធ្វើការងារទៅកាន់ពីរាជធានី/ខេត្តមួយ ទៅរាជធានី/ខេត្តមួយទៀត។ ហើយបុគ្គលិកមានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងបម្រើការងារ ទៅកាន់ខេត្តដាច់ស្រយាលដែលកំពុងខ្វះបុគ្គលិកអប់រំក្រោយពីបានតែងតាំងស៊ុបក្នុងក្របខ័ណ្ឌ។ បុគ្គលិកអប់រំបានបម្រើការងារក្នុងរាជធានី/ខេត្តយ៉ាងតិចរយៈពេល០៣ឆ្នាំ មានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងធ្វើការងារ ពីខេត្តដាច់ស្រយាលទៅកាន់ខេត្តវាលរាប។ ចំពោះបុគ្គលិកបម្រើការងារនៅខេត្តវាលរាបមានអតីតភាពយ៉ាងតិចរយៈពេល០៦ឆ្នាំ និងបុគ្គលិកបម្រើការងារនៅខេត្តដាច់ស្រយាលមានអតីតភាពរយៈពេល០៥ឆ្នាំមានសិទ្ធដាក់ពាក្យសុំផ្លាស់ប្តូរទីកន្លែងបម្រើការងារមកកាន់អង្គភាពក្រោមឱវាទទីស្តីការក្រសួង និងក្រោមឱវាទមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ។ បុគ្គលិកអប់រំដែលជាប់កិច្ចសន្យានៅតំបន់ជួបការលំបាកមានសិទ្ធដាក់ពាក្យទីកន្លែងបម្រើការងារឆ្លងរាជានី/ខេត្ត ឬចូលអង្គភាពក្រោមឱវាទទីស្តីការក្រសួង លុះត្រាតែបានបម្រើការងាររហូតដល់ចប់កិច្ចសន្យារយៈពេល០៥ឆ្នាំ និងបូកបន្ថែមអតីតភាព០១ឆ្នាំសម្រាប់ការផ្លាស់ប្តូរទៅកាន់រាជធានីភ្នំពេញ ឬអង្គភាពក្រោមឱវាទទីស្តីការក្រសួង (សេចក្តីណែនាំលេខ២៨, ២០១៤) ។

## ២.៥.៣ ការផ្លាស់ប្តូរតាមសហព័ន្ធ

(១)ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់ (ចៀសវាងការរៀបការក្លែងក្លាយ) (២) អនុញ្ញាត ឱ្យផ្លាស់ប្តូរតាមសហព័ទ្ធចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតឱ្យផ្លាស់ចូលក្នុងអង្គភាពតែមួយ (៣) គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ទ្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរ បន្ទាប់ពីសាមីខ្លួនបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។ (សេចក្តីណែនាំលេខ៥៣អយក.សណន, ២០១៩) (៤) ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូ ទោះបីតាមសហព័ទ្ធក៏ដោយ (៥) អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិន ហើយ ត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលត្រូវ

ផ្លាស់ចូល ទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន (៦) អនុញ្ញាតឱ្យផ្ទេរក្របខ័ណ្ឌចេញក្រៅក្រសួង ចំនួន ៥០ នាក់ ក្នុង១ឆ្នាំ ដោយមិនគិតការផ្ទេរជាករណីដោយឡែក (៧) មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខ័ណ្ឌ ប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស (៨) ការផ្លាស់ប្តូរពីរាជធានី ខេត្ត ចូលអង្គភាពនានាក្រោមឱវាទ ទីស្តីការក្រសួងត្រូវឆ្លងកាត់ការប្រឡង វាស់ស្ទង់សមត្ថភាព និងឆ្លងកាត់ការធ្វើសម្ភាសន៍ដោយផ្ទាល់ ពីប្រធានអង្គភាពដែលត្រូវផ្លាស់ចូល។

## ២.៦ ការបែងចែកគ្រូបង្រៀនតាមគ្រឹះស្ថានសិក្សា

ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់សាធារណៈរបស់រដ្ឋបាល ក្រសួងអប់រំយុវជន និងកីឡា បានត្រួតពិនិត្យឡើងវិញនូវការគ្រប់គ្រងមន្ត្រីរាជការប្រកបដោយសនិទានកម្ម ក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការឱ្យសមស្របតានិយាមកំណត់មួយ និងការពង្រាយឱ្យដល់ទីកន្លែងដែលមានតម្រូវការបុគ្គលិក។ ដើម្បីឱ្យសម្រេចបានការងារនេះដោយយោងតាមអនុក្រិត្យលេខ ១៩អនកចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៨៦ សេចក្តីណែនាំលេខៈ ១០៤៩អយក សណន ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ លេខៈ ២៧៤៦អយក សណន ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០០ លេខ ៣២៣៨អយក សណន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ លេខ ២៤២អយក សណន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០១ លេខ ១១៣១អយក សណន ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០១ ក្រសួងណែនាំក្នុងការអនុវត្តនិយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យ បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យដូចខាងក្រោមៈ

### គ្រឹះស្ថានសិក្សាចំណេះទូទៅ

ដើម្បីដំណើរការនៃការសិក្សារបស់គ្រឹះស្ថាននីមួយៗ ការបង្រៀន និងរៀន ការងាររដ្ឋបាលរួមទាំងការងារយុវជននៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅនិមួយៗ ប្រើប្រាស់មន្ត្រីរាជការត្រូវបានកំណត់តាមនិយាមដូចខាងក្រោមៈ

### ២.៦.១ ការបែងចែកភារកិច្ចសម្រាប់បុគ្គលិកបង្រៀន

(១)ការកំណត់ម៉ោងបង្រៀនសម្រាប់គ្រូបឋមសិក្សា(៣០ម៉ោងក្នុងមួយសប្តាហ៍) (២) ការកំណត់

ម៉ោងបង្រៀនសម្រាប់គ្រូទទួលបន្ទុកថ្នាក់ (៣) គ្រូមធ្យមសិក្សាបឋមភូមិបង្រៀន ១៥ម៉ោង/សប្តាហ៍(គ្រូធម្មតាបង្រៀន ១៨ម៉/សប្តាហ៍) (៤) គ្រូមធ្យមសិក្សាទុតិយភូមិបង្រៀន ១៣ម៉ោង/សប្តាហ៍(គ្រូធម្មតាបង្រៀន ១៦ម៉/សប្តាហ៍) គ្រូទទួលបន្ទុកថ្នាក់មានតួនាទីជំនួយឱ្យការងារគ្រប់គ្រងថ្នាក់ ការងារយុវជន និងមានភារកិច្ចបង្រៀនសិស្សតាមមុខវិជ្ជា តាមម៉ោងកំណត់ចំពោះមធ្យមសិក្សា (១៣ម៉ោង ឬ១៥ម៉ោង/សប្តាហ៍) ហើយបឋមសិក្សា(៣០ម៉ោង/សប្តាហ៍) ដោយមានភារកិច្ចតាមដានការសិក្សារបស់សិស្ស ស្រង់និងបូកពិន្ទុប្រចាំខែ ឆមាស ប្រចាំឆ្នាំចូលសៀវភៅ និងចូលតារាងលទ្ធផល(ព្រឹត្តិបត្តពិន្ទុ) ធ្វើសៀវភៅតាមដាន សិក្ខាគារិកហើយចុះហត្ថលេខាលើកិច្ចការរដ្ឋបាលទាំងនោះ

**២.៦.២ ការអនុវត្តម៉ោងបន្ថែមសម្រាប់បុគ្គលិកបង្រៀនមធ្យមសិក្សា**

គ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមបានលុះត្រាតែលោកគ្រូ អ្នកគ្រូបានបង្រៀនគ្រប់ម៉ោងកំណត់ជាមុនសិន ពោលគឺគ្រូមធ្យមសិក្សាបឋមភូមិទទួលបន្ទុកថ្នាក់បង្រៀន១៥ម៉ោង/សប្តាហ៍ (គ្រូធម្មតាបង្រៀន ១៨ម៉ោង/សប្តាហ៍) ឯគ្រូមធ្យមសិក្សាទុតិយភូមិទទួលបន្ទុកថ្នាក់បង្រៀន១៣ម៉ោង/សប្តាហ៍ (គ្រូធម្មតាបង្រៀន១៦ម៉ោង/សប្តាហ៍)។ ក្នុងករណីបង្រៀនមិនគ្រប់ម៉ោងកំណត់ខាងលើក្នុងមិខវិជ្ជាណាមួយ លោកគ្រូ អ្នកគ្រូទាំងនោះត្រូវបង្រៀនមុខវិជ្ជាដទៃទៀត ឬត្រូវបង្រៀនឆ្លងភូមិសិក្សាខ្ពស់ជាង ទាបជាងដើម្បីបង្គ្រប់ម៉ោងកំណត់តាមម៉ោងភូមិសិក្សានីមួយៗខាងលើ។ គ្រូមធ្យមសិក្សាបឋមភូមិទទួលបន្ទុកថ្នាក់បង្រៀនឆ្លងភូមិសិក្សាខ្ពស់ជាងក្របខ័ណ្ឌរបស់ខ្លួនត្រូវបង្រៀន១៣ម៉ោង/សប្តាហ៍ (គ្រូធម្មតាបង្រៀន១៦ម៉ោង/សប្តាហ៍) ឯគ្រូមធ្យមសិក្សាទុតិយភូមិទទួលបន្ទុកថ្នាក់បង្រៀនឆ្លងភូមិសិក្សាទាបជាងក្របខ័ណ្ឌរបស់ខ្លួនត្រូវបង្រៀន១៣ម៉ោង/សប្តាហ៍ (គ្រូធម្មតាបង្រៀន១៦ម៉ោង/សប្តាហ៍)ដដែល។ ម៉ោងកំណត់របស់មន្ត្រីអប់រំដែលបង្រៀនមួយមុខវិជ្ជា ចាប់ពី៣កម្រិតថ្នាក់ឡើងទៅ ឬបីមុខវិជ្ជាឡើងទៅដែលរាប់បញ្ចូលទាំងម៉ោងរៀបចំកិច្ចតែងការត្រូវបានទទួលម៉ោងមួយកម្រិតថ្នាក់ ឬមួយមុខវិជ្ជាចំនួន២ម៉ោង(សេចក្តីណែនាំបន្ថែមលេខ៖២៤២ អយក-សណន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០១)។ ចំណែកការគិតននេះមិនរាប់បញ្ចូលមួយកម្រិតថ្នាក់ ឬមួយមុខវិជ្ជាដំបូងដែលជាកាតព្វកិច្ចក្នុងម៉ោងកំណត់របស់គ្រូម្នាក់ៗទេ(គ្រូមធ្យមសិក្សា

បង្រៀនបីកម្រិតថ្នាក់ ឬបីមុខវិជ្ជាមានម៉ោងកំណត់១២ម៉ោង)។ នៅក្នុងគ្រឹះស្ថានសិក្សា ការបង្រៀនម៉ោងបន្ថែមលើមុខវិជ្ជាត្រូវផ្តល់អាទិភាពទី១ទៅបុគ្គលិកបង្រៀន អាទិភាពទី២ទៅនាយក/នាយិកា ឬនាយករង/នាយិការង អាទិភាពទី៣ទៅបុគ្គលិកផ្សេងៗទៀតនៅការិយាល័យ។ នាយកមានភារកិច្ចសម្របសម្រួលការបែងចែកម៉ោងបន្ថែមដោយពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេសនៃមុខវិជ្ជានិមួយៗ ហើយត្រូវមានការឯកភាពពីសាមីបុគ្គលក្នុងអង្គភាពផងដែរ។

### ២.៦.៣ ការប្រើប្រាស់បុគ្គលិកនៅទីចាត់ការនៃសាលារៀន

(១) សាលារៀនមានចំនួនថ្នាក់ចាប់ពី៥ថ្នាក់ ដល់១០ថ្នាក់ត្រូវមាននាយក/នាយិកាមួយនាក់ និងនាយករង/នាយិការងមួយនាក់ សម្រាប់ថ្នាក់ពី៥ ដល់១៤ថ្នាក់ ត្រូវទទួលបន្ថែមការងារយុវជន។ ចាប់ពី១៥ថ្នាក់ឡើងទៅត្រូវមាននាយក/នាយិកាមួយនាក់ និងនាយករង/នាយិការងពីរនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន លេខាធិការមួយនាក់ បណ្ណារក្សមួយនាក់ និងគណនេយ្យមួយនាក់ទទួលបន្ថែមលើការងារបន្ទប់ពិសោធន៍ (២) សាលារៀនមានចំនួនថ្នាក់ចាប់ពី២១ថ្នាក់ ដល់៤០ថ្នាក់ជាសាលាមធ្យម ត្រូវមាននាយក/នាយិកាមួយនាក់ និងនាយករង/នាយិការងពីរនាក់ (សម្រាប់ថ្នាក់ពី២១ ដល់២៩ថ្នាក់ ត្រូវមាននាយករង/នាយិការងពីរនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន។ ចាប់ពី៣០ថ្នាក់ឡើងទៅ ត្រូវមាននាយករង/នាយិការងបីនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន លេខាធិការពីរនាក់ បណ្ណារក្សពីរនាក់ និងគណនេយ្យមួយនាក់ទទួលបន្ថែមលើការងារបន្ទប់ពិសោធន៍ (៣) សាលាមានថ្នាក់ពី៤១ថ្នាក់ ដល់៦០ថ្នាក់ជាសាលាធំ ត្រូវមាននាយក/នាយិកា និងនាយករង/នាយិការងបីនាក់ ក្នុងនោះម្នាក់ទទួលបន្ទុកការងារយុវជន លេខាធិការពីរនាក់ បណ្ណារក្សពីរនាក់ និងគណនេយ្យមួយនាក់ទទួលបន្ថែមលើការងារបន្ទប់ពិសោធន៍ (ព្រះរាជក្រមលេខ០៦/នស/៩៤, ១៩៩៤)។

### ២.៦.៤ ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនដែលទទួលបន្ទុកថ្នាក់

បុគ្គលិកបង្រៀនដែលទទួលបន្ទុកថ្នាក់ត្រូវបានម៉ោងបន្ថែមបំពេញការងារក្នុងមួយសប្តាហ៍ (១) គ្រូកម្រិតមូលដ្ឋានទទួលបានម៉ោងបន្ថែម០៣ម៉ោង/សប្តាហ៍ (២) គ្រូកម្រិតឧត្តមទទួលបានម៉ោងបន្ថែម

០៤ម៉ោង/សប្តាហ៍ (៣)គ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទទួលបានម៉ោងបន្ថែម០៣ម៉ោង/សប្តាហ៍។

**២.៦.៥ ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនបង្រៀនច្រើនកម្រិត ឬច្រើនមុខវិជ្ជា**

បុគ្គលិកបង្រៀននៅមធ្យមសិក្សា ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដែលបង្រៀនមួយមុខវិជ្ជាចាប់ពី ពីរកម្រិតឡើងទៅ ឬពីរមុខវិជ្ជាឡើងទៅត្រូវរាប់បញ្ចូលម៉ោងរៀបចំកិច្ចតែងការបង្រៀនមួយកម្រិត ឬមួយមុខវិជ្ជាស្មើនឹងពីរម៉ោងក្នុងមួយសប្តាហ៍។ ការគិតនេះមិនរាប់បញ្ចូលមួយកម្រិតថ្នាក់ ឬមួយមុខវិជ្ជាដំបូងដែលជាកាតព្វកិច្ចក្នុងម៉ោកំណត់របស់គ្រូម្នាក់ឡើយ។

**២.៦.៦.ម៉ោងកំណត់ប្រចាំសប្តាហ៍របស់បុគ្គលិកបង្រៀនដែលជាប្រធានក្រុមបច្ចេកទេសមុខវិជ្ជានៅសាលាកម្រង សាលាមធ្យមសិក្សាធនធាន ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន**

បុគ្គលិកបង្រៀននៅមធ្យមសិក្សា ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនជាប្រធានក្រុមបច្ចេកទេសមុខវិជ្ជានៅសាលាបង្គោល(កម្រង) សាលាមធ្យមសិក្សាធនធានដែលមានភារកិច្ចដឹកនាំសាលាឧបសម្ព័ន្ធ ឬសាលាបណ្តាញក្នុងការប្រជុំដោះស្រាយបញ្ហាបច្ចេកទេសស្រាវជ្រាវគរុកោសល្យ វិធីសាស្ត្របង្រៀន ថ្នាក់និទ្ទេសន៍ត្រូវបានបន្ថែម០២ម៉ោងក្នុងមួយសប្តាហ៍។

**២.៦.៧.និយាមប្រើប្រាស់បុគ្គលិក ម៉ោងកំណត់ និងម៉ោងបន្ថែម**

បុគ្គលិកបង្រៀននៅមធ្យមសិក្សា ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដែលខ្វះគ្រូបង្រៀនបុគ្គលិកអប់រំទាំងអស់អាចបង្រៀនដោយគិតម៉ោងបន្ថែមបានលុះត្រាតែបុគ្គលិកអប់រំទាំងនោះបានបំពេញម៉ោងកំណត់របស់ខ្លួន ឬក្រុមមុខវិជ្ជារបស់ខ្លួនហើយ១៨ម៉ោង/សប្តាហ៍សម្រាប់គ្រូកម្រិតមូលដ្ឋានធម្មតា និង១៥ម៉ោង/សប្តាហ៍សម្រាប់គ្រូកាន់បន្ទុកថ្នាក់ ១៦ម៉ោង/សប្តាហ៍សម្រាប់គ្រូកម្រិតឧត្តមធម្មតា និង១២ម៉ោង/សប្តាហ៍សម្រប់គ្រូកាន់បន្ទុកថ្នាក់ ១១ម៉ោង/សប្តាហ៍សម្រាប់គ្រូឧទ្ទេសទទួលបន្ទុកថ្នាក់(សាលាគរុកោសល្យ) ៩ម៉ោង/សប្តាហ៍សម្រាប់គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំទទួលបន្ទុកថ្នាក់។ ចំនួនម៉ោងបន្ថែម

មិនឱ្យលើសពី៤៨ម៉ោងក្នុងមួយខែសម្រាប់គ្រូបង្រៀនសុទ្ធសាធ និងមិនឱ្យលើសពី៣២ម៉ោងក្នុងមួយខែសម្រាប់បុគ្គលិកមិនបង្រៀន ឬមន្ត្រីមកពីអង្គភាពផ្សេងៗ (សេចក្ដីណែនាំលេខ៣៣អយក.សណន, ២០១៤)។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ដំណើរការនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងធ្វើឡើងបន្ទាប់ពីឧបករណ៍ស្រាវជ្រាវរៀបចំបានចប់គ្រប់ជ្រុងជ្រោយ ហើយទទួលបានការអនុញ្ញាតតាមលិខិតឧទ្ទេសនាម របស់ **ឯកឧត្តមបណ្ឌិតសៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំក្នុងការចុះធ្វើការសិក្សាស្រាវជ្រាវ ដើម្បីដំណើរការរៀបចំ និងចុះប្រមូលទិន្នន័យនៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី។ បន្ទាប់ពីមានការយល់ព្រមនិងអនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី អ្នកសិក្សាស្រាជ្រាវបានធ្វើការប្រមូលព័ត៌មានពីការិយាល័យដែលពាក់ព័ន្ធមួយចំនួនដូចជា ការិយាល័យគ្រប់គ្រងបុគ្គលិកផ្នែកមធ្យមសិក្សា និងការិយាល័យគ្រប់គ្រងបុគ្គលិកផ្នែកបឋមសិក្សា។ បន្ទាប់មកបញ្ជូនទៅឱ្យការិយាល័យ អប់រំ យុវជន និងកីឡាតាមក្រុង និងស្រុកនានាក្នុងខេត្តមណ្ឌលគិរីនូវលិខិតឧទ្ទេសនាមក្នុងការចុះស្រាវជ្រាវ រួចធ្វើការទំនាក់ទំនងទៅប្រធានការិយាល័យនានាដើម្បីរៀបចំផែនការ និងកាលវិភាគក្នុងកិច្ចដំណើរការចុះប្រមូលទិន្នន័យ ដោយពន្យល់ពីគោលបំណង ដើម្បីជូនដំណឹងដល់នាយក នាយិកាសាលា មុនពេលដំណើរការនៃការចុះប្រមូលទិន្នន័យ ។

## ៣.២ ការជ្រើសរើសគំរូសំណាក

### ទីតាំងភូមិសាស្ត្រ ខេត្តមណ្ឌលគីរី

ខេត្តមណ្ឌលគីរីជាខេត្តមួយដែលស្ថិតនៅភូមិភាគឦសាននៃប្រទេសកម្ពុជា ដែលមានព្រំប្រទល់ខាងកើតជាប់នឹង ប្រទេសវៀតណាមខាងជើងជាប់នឹងខេត្តរតនគីរី ខាងជើងឈៀងខាងលិចជាប់នឹងខេត្តស្ទឹងត្រែងខាងលិចជាប់នឹងខេត្តក្រចេះ ហើយមានចំងាយ ៣៨២គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦, ៧ និង៧៦ដោយឆ្លងកាត់តាមខេត្តកណ្តាល ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម និងក្រចេះ ផ្លូវដែលអាចធ្វើដំណើរទៅដល់ខេត្តមណ្ឌលគីរី បានមានផ្លូវគោក និងផ្លូវអាកាស បើយើង ធ្វើដំណើរតាមផ្លូវគោកយើងនិងឃើញថាកំណាត់ផ្លូវពី ភ្នំពេញទៅមណ្ឌលគិរី ជាផ្លូវ កៅស៊ូដែលផ្តល់នូវលក្ខណះ

ងាយស្រួលក្នុងការធ្វើដំណើរ ។ ខេត្តនេះមានអាកាសធាតុខុសពីខេត្តផ្សេងៗទៀតនៅកម្ពុជា ដោយនៅក្នុងរដូវក្តៅ សីតុណ្ហភាពចាប់ពី ២៧°C ទៅ ៣១°C ដែលអាចចុះត្រជាក់នៅពេលយប់ ខេត្តមណ្ឌលគីរីជាតំបន់ទេសចរណ៍ធម្មជាតិ ធំមួយនៃព្រះរាជាណាចក្រកម្ពុជា ដែលមានតំបន់ទេសចរណ៍ធម្មជាតិជាច្រើនដូចជា ទឹកជ្រោះប្រកបដោយហ្វូងមច្ឆាជាច្រើនប្រភេទ ព្រមទាំង រុក្ខជាតិ សត្វព្រៃ ព្រៃកោងកាង និងភ្នំតូចធំជាច្រើន។

## ប្រជាសាស្រ្ត ខេត្តមណ្ឌលគីរី

ខេត្តមណ្ឌលគីរីមានផ្ទៃដីសរុបទាំងអស់ ១៤២៨៨គីឡូម៉ែត្រការ៉េ ដែលមានប្រជាជនសរុប ៣២៤០៧នាក់ មាន៥៦៥៧គ្រួសារ ប្រុស១៦៣៨០នាក់ និង ស្រី១៦០២៧នាក់ (វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ, ១៩៩៨) ហើយដង់ស៊ីតេប្រជាជនគិតជាមធ្យម ២នាក់ក្នុង ១គីឡូម៉ែត្រការ៉េ អត្រាកំនើនប្រជាជន ០.៣២ភាគរយ។ ខេត្តមណ្ឌលគីរី ជាតំបន់ភ្នំ និង ខ្ពង់រាបស្ថិតនៅប៉ែកឥសាននៃប្រទេសកម្ពុជា ដែលប្រជាពលរដ្ឋភាគច្រើន ជាជនជាតិភាគតិច ខេត្តមណ្ឌលគីរីមានប្រជាជនព្នង ៨០ភាគរយ ក្រៅពីនេះមានជនជាតិចំរុះគ្នាផ្សេងៗទៀត ដូចជា ខ្មែរ ចិន វៀតណាម ថៃ ខ្មែរឥស្លាម និង មាន ជនជាតិភាគតិចមួយចំនួនទៀត ហើយការប្រកបរបរកស៊ីរបស់ពួកគេនៅទីប្រជុំជន គឺទីរួមខេត្តគេប្រកបមុខរបរពាណិជ្ជកម្ម បើនៅឯជនបទវិញគេ ដើរបោចវល្លិ ដើរប្រមាញ់សត្វតាមរបៀបបុរាណ ចំពោះការធ្វើស្រែវិញមានតែនៅស្រុកកោះញែកមួយប៉ុណ្ណោះ គេធ្វើ ស្រែបុកដាំនៅលើខ្នងភ្នំ ដូច្នេះអំណោយផលវាទទួលបានតិចណាស់ព្រោះវាអាស្រ័យទៅលើទឹក ភ្លៀង ប្រសិន បើភ្លៀងធ្លាក់ជោកជាំទើប ដំណាំស្រូវរបស់ពួកគាត់ បានផលល្អ ជីវភាពរបស់ពលរដ្ឋនៅខេត្តមណ្ឌលគីរី មានកំរិតទាបណាស់ក្នុង មួយថ្ងៃមនុស្សម្នាក់មិនអាចរកចំណូល បាន ៥០០រៀលផង។ ក្រៅពីមុខរបរធ្វើស្រែ ប្រជាជនខ្លះទៀតមានមុខរបរ ជាអ្នកចំការ មន្រ្តីរាជការ រីឯខ្លះទៀតប្រកបរបរនៅក្នុងវិស័យទេសចរណ៍ដោយធ្វើការផ្គត់ផ្គង់ដល់សេវាកម្ម ស្នាក់នៅ បំរើសេវាកម្មម្ហូបអាហារ ព្រមទាំងសេវាកម្មបន្ទាប់បន្សំជាច្រើនទៀតផងដែរ។ ប្រជាជន៨០%ជាជនជាតិភាគតិច ជនជាតិដែលមានច្រើនជាងគេគឺជនជាតិព្នង។ នៅសល់២០%ទៀតជាជនជាតិខ្មែរ ចិន និង ចាម។ ប្រជាជននៅទីនោះ

ប្រកបរបរជាចំបងគឺ ដាំដុះស្រូវ ដើមឈើហូបផ្លែ និងបន្លែបង្កាផ្សេងៗ។ ក្រៅពីនេះពួកគេដាំ ស្ត្របឺរី កាហ្វេ កៅស៊ូ និងស្វាយចន្ទី។ ចាប់តាំងពីខេត្តមណ្ឌលគិរីមានការរីកចំរើនមកខេត្តនេះបានធ្វើអោយប្រជាជនមានមុខរបរដើម្បីបង្កើនជីវភាពរស់នៅ ឈានទៅរកការអភិវឌ្ឍ ហើយចម្ងាយផ្លូវក៏តិចជាងមុនដោយអោយនៅសល់ត្រឹម៣៨០គីឡូម៉ែត្រ។ ចំណែកឯប្រជាជនក៏មានគំនិតក្នុងការផ្លាស់ប្តូររបៀបរស់នៅរបស់ពួកគេដែរ។

**តារាងទី៤៖ រដ្ឋបាលខេត្តមណ្ឌលគិរី**

| លេខកូដស្រុក/ក្រុង | ឈ្មោះស្រុក/ក្រុង | ចំនួនឃុំ/សង្កាត់ |
|---|---|---|
| ១១០១ | ស្រុកកែវសីមា | ៥ |
| ១១០២ | ស្រុកកោះញែក | ៦ |
| ១១០៣ | ស្រុកអូររាំង | ២ |
| ១១០៤ | ស្រុកពេជ្រាដា | ៤ |
| ១១០៥ | ក្រុងសែនមនោរម្យ | ៤ |

**ផែនទី ខេត្តមណ្ឌលគីរី**




http://www.cambodia.gov.kh/unisql2/egov/khmer/province/mondol_kiri.html

ក្នុងករណីសិក្សានេះ អ្នកស្រាវជ្រាវបានកំណត់យកសំណាកដើម្បី ធ្វើការស្រាវជ្រាវ (នាយកសាលា/នាយិកាសាលា) ដែលជាគណៈគ្រប់គ្រងសាលាបឋមសិក្សាចំនួន៨៨ អនុវិទ្យាល័យចំនួន០៩ និងវិទ្យាល័យដែលមានអនុវិទ្យាល័យចំនួន០៥ ទូទាំងខេត្តមណ្ឌលគិរីតែប៉ុណ្ណោះ។ ក្នុងនេះដែរអ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីឱ្យលោកនាយក/នាយិកា ឬនាយករង/នាយិការងជ្រើសរើសចម្លើយ ដែលត្រឹមត្រូវដោយបំពេញតារាងសំណួរ បញ្ជីសំណួរ ក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានក្នុងន័យជឿទុកចិត្តបានសម្រាប់និក្ខេបបទ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ និងការប្រមូលទិន្នន័យ

### ៣.៣.១ ឧបករណ៍ស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះប្រើប្រាស់កម្រងសំណួរពីរប្រភេទគឺ (១) កម្រងសំណួរសម្រាប់ឱ្យលោកនាយក/លោកស្រីនាយិកាធ្វើការបំពេញ ក្នុងនោះកម្រងសំណួរត្រូវបានចែកចេញជាពីរផ្នែក ដែលផ្នែកទីមួយគឺសម្រាប់ប្រមូលទិន្នន័យពីការកំណត់ពីតម្រូវការគ្រូនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ និងផ្នែកទីពីរគឺសម្រាប់ប្រមូលទិន្នន័យស្តីពីទស្សនៈរបស់នាយក/នាយិកាលើការជ្រើសរើសគ្រូដើម្បីយកមកធ្វើការវិភាគ(២) ប្រើប្រាស់ Google form សម្រាប់បំពេញតាមប្រព័ន្ធអនឡាញ ។

### ៣.៣.២ ការប្រមូលទិន្នន័យ

បន្ទាប់ពីបានទទួលការណែនាំ នឹងឯកភាពពីសាស្រ្តាចារ្យដឹកនាំ ព្រមទាំងទទួលបានកាអនុញ្ញាតពីឯកឧត្តមនាយកវិទ្យាស្ថានជាតិអប់រំតាមរយៈលិខិតអនុញ្ញាតជាផ្លូវការលេខ១៣៥-វជអ-ផកចុះថ្ងៃពុធ០៧កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក.ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ និងលិខិតជម្រាបរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តមណ្ឌលគិរីលេខ ០៥៩.អយក.ចុះថ្ងៃពុធ ១រោច ខែស្រាពណ៍ ឆ្នាំជូតទោស័ក.ព.ស២៥៦៤ត្រូវនឹងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០។ បន្ទាប់មកអ្នកស្រាវជ្រាវបានរៀបចំទម្រង់លិខិតសុំការអនុញ្ញាត ដើម្បីសម្រួលដល់ការចុះប្រមូលទិន្នន័យ និងកម្រងសំណួរដែលរៀបចំឡើងជាភាសាខ្មែរសម្រាប់ជ្រើសរើសចម្លើយក្នុងការសម្ភាសន៍ដូចខាងក្រោម៖

(១) ដំបូងអ្នកស្រាវជ្រាវបានផ្ញើរលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យទៅកាន់មន្ទីរអប់រំយុវជន និងកីឡាខេត្តមណ្ឌលគិរី ការិយាល័យអប់រំយុវជន និងកីឡាស្រុក-ក្រុង និងផ្ញើជូនទៅគ្រប់សាលាបឋមសិក្សា និងអនុវិទ្យាល័យទាំងអស់ក្នុងខេត្តមណ្ឌលគិរី ដើម្បីសុំការអនុញ្ញាតដោយប្រាប់ពីគោលបំណងពីការស្រាវជ្រាវនេះ។ (២) បន្ទាប់មកអ្នកស្រាវជ្រាវចាប់ផ្តើមធ្វើការណាត់ជួបជាមួយនាយក/នាយិកា ឬនាយករង/នាយិការងតាមរយៈ(Telegram\Google forms និងទូរស័ព្ទដៃ)ដើម្បីធ្វើការបំពេញកម្រងសំណួរ។

## ៣.៤ វិធីសាស្ត្រវិភាគទិន្នន័យ

ការស្រាវជ្រាវនេះ ប្រើទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលតាមរយៈ តារាងលេខ ចំនួន ភាគរយ ដោយវិភាគទិន្នន័យពឹងផ្អែកលើការពណ៌នា និងគណនាយ៉ាងប្រុងប្រយ័ត្នពីអ្នកចូលរួម ហើយការសិក្សាស្រាវជ្រាវនេះសំអាងលើការរកឃើញពីការសម្ភាសន៍ និងការបំពេញកម្រងបញ្ជីសំណួរ។ រីឯទិន្នន័យ តាមបែបគុណវិស័យត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបើកដោយសម្ភាសន៍ ។ ដោយឡែកកម្រងសំណួរបិទត្រូវបានធ្វើឡើងសម្រាប់នាយកឬនាយិកាសាលាបឋមសិក្សា និងអនុវិទ្យាល័យបំពេញស្ថិតិរបស់សាលាចូលទៅក្នុងកម្រងសំណួរ។ ចំពោះការវិភាគទិន្នន័យបែបបរិមាណវិស័យ គឺវិភាគតាមក្រាហ្វិក(Graphics) និងតារាងដោយប្រើកម្មវិធី Microsoft Excel ។ រីឯការវិភាគទិន្នន័យបែបគុណវិស័យ គឺវិភាគតាមរយៈការចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកទៅលើទស្សនៈ និងអត្ថន័យនៃប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែល លគ្នា រួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។

## ៣.៥ និតិវិធី (ក្រមសីលធម៌) ឬដំណើរការប្រមូលទិន្នន័យ

មុនចុះប្រមូលទិន្នន័យតាមទីកន្លែងដែលបានជ្រើសរើស អ្នកស្រាវជ្រាវ ត្រូវមានការសុំអនុញ្ញាត ជាលិខិតបេសកម្ម ពីប្រធានអង្គភាព (មន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ក្រុង) ការិយាល័យស្រុក/ខណ្ឌ យល់ព្រម និងឯកភាព ពីគណៈគ្រប់គ្រងសាលាគោលដៅទាំងអស់។ អ្នកសិក្សាស្រាវជ្រាវត្រូវមានឯកសារ លិខិតបេសកម្ម និងកម្រងសំណួរជាប់ខ្លួន ក្នុងការប្រមូលទិន្នន័យ ដោយសុំការអនុញ្ញាត ពីអ្នកចូលរួមផ្តល់

ទិន្នន័យ តាមរយៈកាតកត់ត្រាពាក្យសម្តី ថតជាសម្លេង និងរូបភាពក្តី ដោយគ្មានការបង្ខិតបង្ខំទេ លុះត្រាតែមានការអនុញ្ញាតពីពួកគាត់ ហើយពួកគាត់អាចមានសិទ្ធក្នុងការផ្តល់ចម្លើយ និងមិនអាចផ្តល់ចម្លើយក្នុងលក្ខខណ្ឌណាមួយ។

មុនពេលប្រមូលទិន្នន័យអ្នកស្រាវជ្រាវត្រូវធ្វើកិច្ចគារវៈសុំការអនុញ្ញតពីប្រធានអង្គភាព និងការអនុម័តពីវិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំយុវជន និងកីឡា បន្ទាប់មកអ្នកស្រាវជ្រាវធ្វើលិខិតអនុញ្ញតជាមួយគោលបំណងនៃការស្រាវជ្រាវដ៏ជាក់លាក់មួយ ទៅកាន់អង្គភាពពាក់ព័ន្ធដូចជាៈប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តមណ្ឌលគិរី ប្រធានការិយាល័យ អប់រំយុវជន និងកីឡាស្រុក/ក្រុង នាយក/នាយិកានៃសាលាក្នុងខេត្តនេះដោយស្នើសុំការយល់ព្រមពីពួកគាត់ ដើម្បីបង្ហាញពីឆន្ទៈចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះដោយសេរី។

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវ

## ៤.១. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា

### ៤.១.១.ស្ថានភាពទីតាំងសាលាបឋមសិក្សា

តារាងទី៥ ៖ ចំនួនសាលារៀនដែលស្ថិតនៅតំបន់ទីប្រជុំជន តំបន់ជនបទ និងតំបន់ជួបការលំបាក

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| 1 | ទីតាំងសាលារៀន | តំបន់ទីប្រជុំជន | 3 | 3.40% |
| | | តំបន់ជនបទ | 28 | 31.82% |
| | | តំបន់ជួបការលំបាក | 57 | 64.78% |
| | | សរុប | 88 | 100% |

តាមតារាងទី៥ខាងលើ បង្ហាញថាសាលារៀនដែលស្ថិតនៅទីប្រជុំជនមានចំនួន៣សាលា ស្មើនឹង៣.៤០% នៅតំបន់ជនបទមានចំនួន២៨សាលា ស្មើនឹង៣១.៨២% និងនៅតំបន់ជួបការលំបាកមានចំនួន៥៧ ស្មើនឹង៦៤.៧៨% ។

### ៤.១.២. ការកំណត់ពីតម្រូវការគ្រូបឋមសិក្សា

#### ៤.១.២.១. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាទូទាំងខេត្ត



**ក្រាហ្វទី១ ៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង**

ក្រាហ្វទី១៖ បានបង្ហាញអោយឃើញថាសាលាបឋមសិក្សាទាំង៨៨នៅក្នុងខេត្តមណ្ឌលគិរី ចំនួនជាក់ស្តែង សិស្សពីថ្នាក់ទី១ ដល់ទី៦មានចំនួន១៤,៧៣០នាក់ ថ្នាក់ជាក់ស្តែងសរុបចំនួន ៦៥៨ថ្នាក់ គ្រូបង្រៀនជាក់ស្តែងចំនួន៥៨២នាក់ បើធៀបនឹងថ្នាក់រៀនគ្រូម្នាក់ថ្នាក់មួយ មានតម្រូវការគ្រូជាក់ស្តែង ខ្វះគ្រូចំនួន៧៦នាក់។ បើគិតតាមនិយាមអប្បបរមាសិស្សថ្នាក់ទី១,២,៣ក្នុងមួយថ្នាក់៣៥នាក់ (៨៤៨៩ចែក៣៥នាក់ស្មើ២៤៣ថ្នាក់)សិស្សថ្នាក់ទី៤,៥,៦ក្នុងមួយថ្នាក់៤០នាក់(៦,២៤១ចែក៤០នាក់ស្មើ១៥៦ថ្នាក់) សរុបពីថ្នាក់ទី១-៦មានចំនួន៣៩៩ថ្នាក់(២៤៣បូក១៥៦) បើធៀបនឹងគ្រូបង្រៀនជាក់ស្តែងមានន័យថាតម្រូវការគ្រូលើស១៨៣ ចំនួននាក់ (៥៨២ ដក ៣៩៩)។

បើគិតតាមនិយាមអតិបរមា សិស្សថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៤៥នាក់ ( ៨,៤៨៩ ចែក ៤៥នាក់ ស្មើ ១៨៩ថ្នាក់) សិស្សថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៥០នាក់ (៦,២៤១ ចែក ៥០នាក់ ស្មើ ១២៥ថ្នាក់) សរុបពីថ្នាក់ទី១-៦ មានចំនួន ៣១៤ថ្នាក់ (១៨៩ បូក ១២៥) បើធៀប នឹងគ្រូបង្រៀនជាក់ស្តែងមានន័យ ថាតម្រូវការគ្រូ លើសចំនួន ២៦៨នាក់ (៥៨២ ដក ៣១៤ ) ។

សរុបលទ្ធផលមកឃើញថាការប្រើប្រាស់គ្រូនៅសាលាបឋមសិក្សាក្នុងខេត្តមណ្ឌលគិរីពុំទាន់សមស្របតាមគោលដៅដែលក្រសួងអប់រំ យុវជននិងកីឡាដាក់ឱ្យអនុវត្តនៅឡើយទេដោយសារការពង្រាយគ្រូទៅតាមតំបន់មួយចំនួន មិនទាន់បានគ្រប់គ្រាន់ បើធៀបនឹងតម្រូវការជាក់ស្តែងនិងតាមនិយាមគឺនៅខ្វះតិចតួចសាលាខ្លះនៅខេត្តមណ្ឌលគិរីជាសាលាដែលស្ថិតនៅតាម តំបន់ដាច់ស្រយាល ជួបការលំបាកនិងឆ្ងាយពីទីប្រជុំជននិងផ្លូវជាតិ រីឯផ្លូវចូលទៅក្នុងភូមិ ខ្លះទៀតឆ្លងស្ទឹងឆ្លងអូរពេលរដូវវស្សាដាច់ផ្លូវលិចទឹកគ្រូទៅពីចម្ងាយពិបាករកកន្លែងស្នាក់នៅ គ្រូបង្រៀនជាស្ត្រីមានតិចតួចបំផុត សាលាខ្លះគ្មានគ្រូបង្រៀនជាស្ត្រីទេ ជាហេតុធ្វើឱ្យខ្វះគ្រូនៅ តំបន់ទាំង នោះ ឯតំបន់ប្រជុំជនបែរជាលើស ។ មធ្យោបាយរបស់មន្ទីរខេត្តបើសិស្សតិច ឬខ្វះបន្ទប់ ប្រើថ្នាក់គួប សិស្សច្រើន ប្រើ២ពេល និងគ្រូកិច្ចសន្យា និងប្រើគោលការណ៍ខ្ចីតាម

កម្រង ឬមត្តេយ្យបើសាលា ណា ខ្វះគ្រូ តាមសេចក្តីណែនាំលេខ៖៥៣ អយក.សណន ស្តីពីការគ្រប់គ្រងគ្រូបង្រៀន ។

### ៤.១.២.២.ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាក្រុងសែនមនោរម្យ




**ក្រាហ្វទី២៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង**

ក្រាហ្វទី២៖បានបង្ហាញអោយឃើញថាសាលាបឋមសិក្សានៅក្នុងក្រុងសែនមនោរម្យចំនួនជាក់ស្តែង សិស្សពីថ្នាក់ទី១ ដល់ទី៦ មាន ២,២៣៩នាក់ ថ្នាក់ជាក់ស្តែងសរុប៧៥ថ្នាក់ គ្រូបង្រៀនចំនួន ៧១នាក់ បើធៀបនឹង ថ្នាក់រៀន គ្រូម្នាក់ ថ្នាក់មួយ (និយាមលេខ៖ ២៥៦ អយក.សណន) មានន័យថាតម្រូវការ គ្រូជាក់ស្តែង ខ្វះគ្រូចំនួន៤នាក់ (៧៥ ដក ៧១នាក់) ។

គិតតាមនិយាមអប្បបរមាវិញ សិស្សថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៣៥នាក់ (១២៧៣ ចែក ៣៥នាក់ ស្មើ ៣៦ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៤០នាក់ (៩៦៦ ចែក ៤០នាក់ ស្មើ ២៤ ថ្នាក់) សរុបចំនួនថ្នាក់ទី១-៦ មាន៦០ថ្នាក់ (៣៦ បូក ២៤) បើធៀបនឹងគ្រូបង្រៀន មានជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន១១នាក់(៧១ដក៦០) មានន័យថាបើសាលាប្រើនិយាមអប្បបរមាមានតែសាលាភាគតិចប៉ុណ្ណោះដែលលើសគ្រូ ដោយសារសាលាទាំងនោះស្ថិតនៅក្បែរក្រុងហើយសំបូរតែបងប្អូនជនជាតិភាគតិចរស់នៅ (តាមជើងភ្នំ) និង ជួបការលំបាក ។

គិតតាមនិយាមអតិបរមា សិស្ស ថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៤៥នាក់ (១២៧៣ ចែក ៤៥នាក់ ស្មើ ២៨ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៥០នាក់ (៩៦៦ ចែក ៥០នាក់ ស្មើ ១៩ ថ្នាក់) សរុបពីថ្នាក់ទី១-៦ មានចំនួន ៤៧ថ្នាក់ (២៨ បូក ១៩) បើធៀបនឹងគ្រូបង្រៀនមាន ជាក់ស្តែង មានន័យថាតម្រូវការគ្រូ លើសចំនួន២៤នាក់ (៧១ ដក ៤៧)។

សន្និដ្ឋានជារួមមក ការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សានៅក្រុងសែនមនោរម្យតាមជាក់ស្តែងខ្វះគ្រូ តែបើគិតតាមនិយាម មានចំនួនគ្រូលើស នៅតាមតំបន់ប្រជុំជន មានន័យថាក្រុងសែនមនោរម្យ មិនទាន់បានសមស្របនៅឡើយនោះទេ។

### ៤.១.២.៣. ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកអូររាំង




**ក្រាហ្វទី៣ ៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង**

ក្រាហ្វទី៣៖ បានបង្ហាញអោយឃើញថាសាលាបឋមសិក្សានៅក្នុងស្រុកអូររាំង ចំនួនជាក់ស្តែង សិស្សពីថ្នាក់ទី១ដល់ទី៦ មាន១០៣១នាក់ ថ្នាក់ជាក់ស្តែង ៦៧សរុបថ្នាក់ គ្រូបង្រៀនចំនួន៥២នាក់ បើធៀបនឹង ថ្នាក់រៀន គ្រូម្នាក់ ថ្នាក់មួយ (និយាមលេខ៖ ២៥៦ អយក.សណន) មានន័យថាតម្រូវការ គ្រូជាក់ស្តែង ខ្វះគ្រូចំនួន១៥នាក់ (៦៧ ដក ៥២នាក់) ។

គិតតាមនិយាមអប្បបរមាវិញ សិស្សថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៣៥នាក់ (៦០២ ចែក ៣៥នាក់ ស្មើ១៧ថ្នាក់) សិស្សថ្នាក់ទី៤,៥,៦ក្នុងមួយថ្នាក់៤០នាក់ (៤២៩ចែក៤០នាក់ ស្មើ១១ថ្នាក់) សរុបចំនួនថ្នាក់ទី១-៦ មាន២៨ថ្នាក់ (១៧ បូក ១១) បើធៀបនឹងគ្រូបង្រៀន មានជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន២៤នាក់(៧១ដក៦០)។

គិតតាមនិយាមអតិបរមា សិស្ស ថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៤៥នាក់ (៦០២ ចែក ៤៥នាក់ ស្មើ ១៣ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៥០នាក់ (៤២៩ ចែក ៥០នាក់ ស្មើ ៩ថ្នាក់) សរុបពីថ្នាក់ទី ១-៦ មានចំនួន ២២ថ្នាក់ (១៣ បូក ៩) បើធៀបនឹងគ្រូបង្រៀនមាន ជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន៣០នាក់( ៥២ ដក ៣០)។

សន្និដ្ឋានជារួមមក ការប្រើប្រាស់គ្រូបង្រៀនបឋមតាមនិយាម មានចំនួនលើសគ្រូនៅតាមតំបន់មួយចំនួនដោយសារស្ថានភាពសាលាជួបការលំបាក ដាច់ស្រយាលការស្នើសុំមិនបានគ្រប់តាមតម្រូវការ ដំណោះស្រាយពួកគាត់គឺប្រើគ្រូកិច្ចសន្យាក្នុង សហគមន៍ ម្យ៉ាងទៀតភូមិនីមួយៗ នៅដាច់ឆ្ងាយពីគ្នាជាហេតុធ្វើឱ្យសហគមន៍ ត្រូវបង្កើតសាលារៀនដើម្បីឱ្យកុមារដែលគ្រប់អាយុបានសិក្សារៀនសូត្រ ទោះបីជាសិស្សមិនគ្រប់ចំនួនតាមនិយាមផលធៀប ថ្នាក់ សិស្ស គ្រូក៏ដោយ។

### ៤.១.២.៤.ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកកោះញែក



**ក្រាហ្វទី៤៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា៤៥-៥០ (ទី១-៣/ទី៤-៦) និងតាមជាក់ស្តែង**

ក្រាហ្វទី៤៖ បានបង្ហាញអោយឃើញថាសាលាបឋមសិក្សានៅក្នុងស្រុកកោះញែក ចំនួនជាក់ស្តែងសិស្ស ពីថ្នាក់ទី១ដល់ទី៦មាន៣៦១៤នាក់ ថ្នាក់ជាក់ស្តែងសរុប១៧៧ថ្នាក់ គ្រូបង្រៀនចំនួន ១៥៦ នាក់បើធៀបនឹង ថ្នាក់រៀនគ្រូម្នាក់ថ្នាក់មួយ(និយាមលេខ៖២៥៦អយក.សណន) មានន័យថាតម្រូវការគ្រូជាក់ស្តែង ខ្វះគ្រូចំនួន២១នាក់ (១៧៧ ដក ១៥៦នាក់)។

គិតតាមនិយាមអប្បបរមាវិញ សិស្សថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៣៥នាក់ (២,០១៥ ចែក ៣៥ នាក់ ស្មើ ៥៨ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៤០នាក់ (១៥៩៩ ចែក ៤០នាក់ ស្មើ៤០ ថ្នាក់) សរុបចំនួនថ្នាក់តាមនិយាមពីទី១-៦ មាន៩៨ថ្នាក់ (៥៨ បូក ៤០) បើធៀបនឹងគ្រូបង្រៀន មានជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន ៥៨នាក់ (១៥៦ ដក ៩៨)។ មានន័យថាបើ សាលា ក្នុងស្រុកកោះញែកប្រើនិយាមអប្បរមា មានសាលាមួយចំនួនដែលលើស សាលាដាច់ស្រយាល (តាមជើងភ្នំ) និង ជួបការលំបាក ហើយសាលាមួយចំនួនទៀតខ្វះតិចតួច។

គិតតាមនិយាមអតិបរមា សិស្ស ថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៤៥នាក់ (២,០១៥ ចែក ៤៥នាក់ ស្មើ ៤៥ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៥០នាក់ (១,៥៩៩ ចែក ៥០នាក់ ស្មើ ៣២ថ្នាក់) សរុបចំនួនថ្នាក់តាមនិយាមថ្នាក់ទី១-៦ មានចំនួន ៧៧ថ្នាក់ (៤៥ បូក ៣២) បើធៀបនឹងគ្រូបង្រៀនមាន ជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន៧៩នាក់(១៥៦ ដក ៧៧)។

សន្និដ្ឋានជារួមមក ការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សានៅស្រុកកោះញែកមានចំនួនលើសគ្រូបើគិតតាមនិយាមកំណត់ចំនួនគ្រូបង្រៀនសាលាខ្លះលើស និងសាលាខ្លះខ្វះគ្រូ នេះបញ្ជាក់ថាការបែងចែកគ្រូ សិស្ស ថ្នាក់តាមសាលានីមួយៗមិនសមស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ យុវជននិងកីឡា ហើយអនុវត្តមិនបានពេញលេញតាមបទដ្ឋានគតិយុត្តិនានារបស់ក្រសួងអប់រំស្តីពីការបែងចែកបុគ្គលិក។

### ៤.១.២.៥. ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកពេជ្រាដា




**ក្រាហ្វទី៥៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥-៤០ (ទី១-៣/៤-៦) និងនិយាមអតិបរមា ៤៥-៥០(ទី១-៣/ទី៤-៦) និងតាមជាក់ស្ដែង**

ក្រាហ្វទី៥៖ បានបង្ហាញអោយឃើញថាសាលាបឋមសិក្សានៅក្នុងស្រុកពេជ្រាដា ចំនួនជាក់ស្ដែងសិស្សពីថ្នាក់ទី១ដល់ទី៦មាន ៣០៩៨នាក់ថ្នាក់ជាក់ស្ដែង សរុប១២៣ថ្នាក់ គ្រូបង្រៀនជាក់ស្ដែង ១១៤នាក់ បើធៀបនឹង ថ្នាក់រៀន គ្រូម្នាក់ ថ្នាក់មួយ (និយាមលេខ៖ ២៥៦ អយក.សណន) មានន័យថា តម្រូវការ គ្រូជាក់ស្ដែង ខ្វះគ្រូ ៩នាក់ (១២៣ ដក ១១៤នាក់) ។

គិតតាមនិយាមអប្បបរមាវិញ សិស្សថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៣៥នាក់ (១,៧៨៤ ចែក ៣៥នាក់ ស្មើ ៥១ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៤០នាក់ (១,៣១៤ ចែក ៤០នាក់ ស្មើ៣៣ ថ្នាក់) សរុបចំនួនថ្នាក់តាមនិយាមពីទី១-៦ មាន៨៤ថ្នាក់ (៥១ បូក ៣៣) បើធៀបនឹងគ្រូបង្រៀន មានជាក់ស្ដែង មានន័យថាតម្រូវការគ្រូលើសចំនួន ៣០នាក់ (១១៤ ដក ៨៤)។

គិតតាមនិយាមអតិបរមា សិស្ស ថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៤៥នាក់ (១,៧៨៤ ចែក ៤៥នាក់ ស្មើ ៤០ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៥០នាក់ (១,៣១៤ ចែក ៥០នាក់ ស្មើ ២៦ថ្នាក់) សរុប

ចំនួនថ្នាក់តាមនិយាមថ្នាក់ទី១-៦ មានចំនួន ៦៦ថ្នាក់ (៩០ បូក ២៦) បើធៀបនឹងគ្រូបង្រៀនមាន ជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន៤៨នាក់(១១៤ ដក ៦៦)។

សន្និដ្ឋានជារួមមក ការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សានៅស្រុកពេជ្រាដាមានចំនួនលើសគ្រូបើគិតតាមនិយាមកំណត់ចំនួនគ្រូបង្រៀនសាលាខ្លះលើស និងសាលាខ្លះខ្វះគ្រូ ដោយសាលាភាគច្រើនចំនួនសិស្សមានតិចនៅតាមកម្រិតថ្នាក់ នេះបញ្ជាក់ថាការបែងចែកគ្រូ សិស្ស ថ្នាក់តាមសាលានីមួយៗមិនសមស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ។

### ៤.១.២.៦.ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅបឋមសិក្សាស្រុកកែវសីមា




**ក្រាហ្វទី៦ ៖ ស្ថិតិផលធៀបនឹងនិយាមអប្បបរមា ៣៥ (សិស្សថ្នាក់ទី១-៣) ៤០(សិស្សថ្នាក់ទី៤-៦) និយាមអតិបរមា ៤៥(សិស្សថ្នាក់ទី១-៣) ៥០(សិស្សថ្នាក់ទី៤-៦) និងតាមជាក់ស្តែង**

ក្រាហ្វទី៥៖ បានបង្ហាញអោយឃើញថាសាលាបឋមសិក្សានៅក្នុងស្រុកកែវសីមា ចំនួនជាក់ស្តែងសិស្សពីថ្នាក់ទី១ដល់ទី៦មាន ៤,៧៤៨នាក់ ថ្នាក់ជាក់ស្តែង សរុប២១៦ថ្នាក់ គ្រូបង្រៀនជាក់ស្តែង ១៨៩នាក់ បើធៀបនឹង ថ្នាក់រៀន គ្រូម្នាក់ ថ្នាក់មួយ (និយាមលេខ៖ ២៥៦ អយក.សណន) មានន័យថា តម្រូវការ គ្រូជាក់ស្តែង ខ្វះគ្រូ ២៧នាក់ (២១៦ ដក ១៨៩នាក់) ។

គិតតាមនិយាមអប្បបរមាវិញ សិស្សថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៣៥នាក់ (២,៨១៥ ចែក ៣៥ នាក់ ស្មើ ៨០ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៤០នាក់ (១,៩៣៣ ចែក ៤០នាក់ ស្មើ៤៨ថ្នាក់)

សរុបចំនួនថ្នាក់តាមនិយាមពីទី១-៦ មាន១២៨ថ្នាក់(៨០បូក៤៨) បើធៀបនឹងគ្រូបង្រៀន មានជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន ៦១នាក់ (១៨៩ ដក ១២៨ )។ មានន័យថាបើ សាលា ក្នុងស្រុកកែវសីមាប្រើនិយាមអប្បរមា មានសាលាមួយចំនួនដែលខ្វះគ្រូ សាលាដាច់ស្រយាល (តាមជើងភ្នំ) និង ជួបការលំបាកដាច់ស្រយាល ពីភូមិមួយទៅភូមិនៅដាច់ឆ្ងាយពីគ្នា ពិបាកធ្វើដំណើរ ការស្នើសុំមិនបានគ្រប់តាមតម្រូវការដំណោះស្រាយពួកគាត់គឺប្រើគ្រូកិច្ចសន្យាក្នុងសហគមន៍ ជាពិសេសដោយសារតែចំនួនកុមារក្នុងថ្នាក់នីមួយៗមានតិចមិនគ្រប់តាមនិយាម ប៉ុន្តែតម្រូវឱ្យមានគ្រូបង្រៀនតាមកម្រិតថ្នាក់នីមួយៗ។

គិតតាមនិយាមអតិបរមា សិស្ស ថ្នាក់ទី១,២,៣ ក្នុងមួយថ្នាក់៤៥នាក់ (២,៨១៥ចែក ៤៥នាក់ស្មើ ៦៣ថ្នាក់) សិស្ស ថ្នាក់ទី៤,៥,៦ ក្នុងមួយថ្នាក់៥០នាក់ (១៩៣៣ ចែក ៥០នាក់ ស្មើ ៣៩ថ្នាក់) សរុបចំនួនថ្នាក់តាមនិយាមថ្នាក់ទី១-៦ មានចំនួន១០២ ថ្នាក់ (៦៣ បូក ៣៩) បើធៀបនឹងគ្រូបង្រៀនជាក់ស្តែង មានន័យថាតម្រូវការគ្រូលើសចំនួន៨៧នាក់(១៨៩ ដក ១០២)។

សន្និដ្ឋានជារួមមក ការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សានៅស្រុកកែវសីមាមានចំនួនលើសគ្រូច្រើនបើគិតតាមនិយាម ប៉ុន្តែជាក់ស្តែងខ្វះគ្រូ នេះបញ្ជាក់ថាការបែងចែកគ្រូ សិស្ស ថ្នាក់តាមសាលានីមួយៗមិនសមស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ យុវជននិងកីឡា ហើយអនុវត្តមិនបានពេញលេញតាមបទដ្ឋានគតិយុត្តិនានារបស់ក្រសួងអប់រំស្តីពីការបែងចែកបុគ្គលិក ដោយសារស្ថានភាពសាលាជួបការលំបាកដាច់ស្រយាល ពីភូមិមួយទៅភូមិនៅដាច់ឆ្ងាយពីគ្នា ពិបាកធ្វើដំណើរ ជាពិសេសដោយសារតែចំនួនកុមារក្នុងថ្នាក់នីមួយៗមានតិចមិនគ្រប់តាមនិយាម ប៉ុន្តែតម្រូវឱ្យមានគ្រូបង្រៀនតាមកម្រិតថ្នាក់។

### ៤.១.៣. ទស្សនៈរបស់នាយក/នាយិកាលើការប្រើប្រាស់គ្រូបឋមសិក្សា



## ក្រាហ្វទី ៧៖ ការស្នើសុំគ្រូរយៈពេល៥ឆ្នាំចុងក្រោយ

ក្រាហ្វទី៧ ៖ បង្ហាញឱ្យឃើញថាតាមការស្រង់មតិរបស់នាយកសាលាចំនួន ៨៨នាក់ក្នុង ចំណោម ៨៨សាលា (៨៨នាក់) ក្នុងខេត្តមណ្ឌលគិរី ការស្នើសុំបន្ថែមគ្រូក្របខណ្ឌបឋមសិក្សារយៈពេល៥ឆ្នាំចុងក្រោយនេះ ២៤ភាគរយ ទទួលគ្រប់ចំនួន , ៣៦ភាគរយ ទទួលបានខ្លះ និង ៤០ភាគរយមិនទទួលបាន ។ បើគិតទៅលើភាគរយដែលខ្ពស់ជាងគេ មិនបានទទួល បញ្ជាក់ថា សាលាដែលនៅតាមតំបន់ដាច់ស្រយាល និងសាលាមានសិស្សតិច មិនសូវមានគ្រូថ្មីបន្ថែមចូល គ្រូថ្មី មកតែ១ឆ្នាំ ឬ ២ឆ្នាំ ដូរចេញទៅវិញ ការជ្រើសរើសគ្រូបណ្តុះបណ្តាល និងបែងចែកគ្រូមានចំនួនកំណត់ ជាហេតុធ្វើអោយសាលាខ្លះលើស និងសាលាខ្លះទៀតខ្វះគ្រូ ចំនួនសិស្សមិនគ្រប់តាមនិយាម ដែលមិនអាចស្នើសុំបន្ថែមបាន។




## ក្រាហ្វទី៨៖ ដំណោះស្រាយបញ្ហាប្រឈមលើស ឬខ្វះគ្រូ របស់នាយក/នាយិកាសាលា

ក្រាហ្វទី៨៖ បង្ហាញថា មតិដំណោះស្រាយរបស់លោកនាយក/នាយិកា បញ្ហាប្រឈមករណីលើសគ្រូ៥១ភាគរយ ស្នើទៅការិយាល័យស្រុកសុំពង្រាយទៅសាលាខ្វះគ្រូ, ៦ភាគរយ ដាក់ជួយបណ្ណាល័យ ឬ រោងជាង, ២៨ភាគរយ ទៅជាជំនួយការ ឬលេខាក្នុងទីចាត់ការ និង១៥ភាគរយ មិនឆ្លើយ ដោយសារសាលារបស់ពួកគាត់មិនមានគ្រូលើស។ ឯបញ្ហាប្រឈមនិងករណីខ្វះវិញ ២៣ភាគរយ ប្រើគ្រូកិច្ចសន្យា

(សិស្សច្រើន), ២៨ភាគរយ ប្រើថ្នាក់គួប (សិស្សតិច ឬខ្វះបន្ទប់), ១៥ភាគរយ ស្នើសុំគ្រូថ្មីបន្ថែម, ៣០ ភាគរយ ប្រើគ្រូពីរពេល(សិស្សច្រើន, ខ្វះគ្រូនិងខ្វះគ្រូ) និង៤ភាគរយ ចម្លើយមិនយកជាការ។

សរុបមកវិញឃើញថាភាគរយដែលជាដំណោះស្រាយខ្ពស់ជាងគេ ការស្នើសុំពង្រាយគ្រូ (ករណីលើសគ្រូ), រីឯការប្រើគ្រូ២ពេល និងប្រើថ្នាក់គួប និងគ្រូកិច្ចសន្យា ករណីខ្វះគ្រូ ដំណោះស្រាយទាំងនេះ យោងតាមសេចក្តីណែនាំលេខ៖ ៥៣ អយក.សណន ស្តីពីការគ្រប់គ្រងគ្រូបង្រៀន ។




**ក្រាហ្វទី៩៖ អនុសាសន៍របស់នាយកសាលា ចំពោះក្រសួងអប់រំ យុវជន និងកីឡា**

ក្រាហ្វទី៩៖ បង្ហាញពីអនុសាសន៍ របស់នាយក/នាយិកាទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីខ្វះគ្រូ និងលើសគ្រូ ។

ករណីខ្វះគ្រូ ឃើញថា ៤៩%ភាគរយ ត្រូវការផ្តល់គ្រូថ្មីបន្ថែម, ២៤ភាគរយ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍, ២៤ភាគរយការស្នើបញ្ចូលក្របខ័ណ្ឌ (ទាំងគ្រូក្របខ័ណ្ឌ និងគ្រូបង្រៀនកិច្ចសន្យា) និង១៤ភាគរយ បង្កើនប្រាក់ឧបត្ថម្ភសម្រាប់ការពង្រាយ គ្រូឆ្លង រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ករណីលើសគ្រូ ឃើញថា ៣៤ភាគរយត្រូវការផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍ រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយទៅសាលាដែលកំពង់ខ្វះគ្រូ, ២៩ភាគរយ ផ្តល់ឱ្យនូវកាំប្រាក់ ១ឆ្នាំម្តង

ឬប្រាក់បំណាច់មុខងារពិសេស ដល់គ្រូស្ម័គ្រចិត្តពង្រាយនៅតំបន់ ជួបការលំបាក, ២៤ភាគរយ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង និង ១៣ភាគរយទៀត លើកទឹកចិត្ត ដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ។

សរុបមកតាមអនុសាសន៍របស់លោកនាយក/នាយិកា ដែលមានភាគរយខ្ពស់ និងអ្វីដែលជាបំណង ចម្បងរបស់ពួកគាត់ ផ្តល់គ្រូក្របខ័ណ្ឌបឋមសិក្សាថ្មីបន្ថែម ក្នុងករណីខ្វះគ្រូ និងផ្តល់ប្រាក់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សរ៍ប្រចាំខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយទៅតំបន់ខ្វះគ្រូ និងជួបការលំបាក។

## ៤.២. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ

### ៤.២.១. ស្ថានភាពទីតាំងសាលារៀនសម្រាប់អនុវិទ្យាល័យ

**តារាងទី៦៖ ចំនួនសាលារៀនដែលស្ថិតនៅតំបន់ទីប្រជុំជន តំបន់ជនបទ និងតំបន់ជួបការលំបាក**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| 1 | ទីតាំងសាលារៀន | តំបន់ទីប្រជុំជន | 4 | 28.57% |
| | | តំបន់ជនបទ | 7 | 50% |
| | | តំបន់ជួបការលំបាក | 3 | 21.43% |
| | | សរុប | 14 | 100% |

### ៤.២.២ ការកំណត់ពីតម្រូវការគ្រូ នៅអនុវិទ្យាល័យ (តាមនិយាមថ្មីលេខ២០)

#### ៤.២.២.១ ស្ថានភាពនៃការប្រើប្រាស់គ្រូ នៅអនុវិទ្យាល័យទូទាំងខេត្តមណ្ឌលគិរី

តារាងទី៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៣២៩៨ នាក់ | |
| ថ្នាក់ | ៨២ ថ្នាក់ | ៧៤ ថ្នាក់ |

| | | |
|---|---|---|
| ម៉ោង | ៣២៩៨ ម៉ោង | ២៩៦០ ម៉ោង |
| គ្រូ | ១៨៣ នាក់ | ១៦៤ នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១៦៦ នាក់ | |
| គ្រូលើស ឬខ្វះ | -១៧ នាក់ | ២ នាក់ |

ជាក់ស្តែង ១៦៦នាក់នៅឆ្នាំសិក្សា ២០១៩-២០២០។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ៨២ថ្នាក់(៣២៩៨ចែកនឹង៤០) និង តាមក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយ សប្តាហ៍ចំនួន៣២៩៨ម៉ោង(៨២គុណនឹង៤០)ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន១៨៣នាក់(៣២៩៨ចែកនឹង១៨) បើតាមនិយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោង ក្នុងមួយសប្តាហ៍។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន ៨ថ្នាក់ (៨២ ដកនឹង ៧៤)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ខេត្តមណ្ឌលគិរីដែលមានសំណាកទាំង១៤ មិនទាន់គោរពបានតាមនិយាម សិស្សថ្នាក់ ដែលកំណត់ដោយតារាងទី៧ បានមកពីការជ្រើសរើសសំណាកពី វិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយ ០៥និងអនុវិទ្យាល័យ ចំនួន ០៩ សាលា ក្នុងក្រុង/ ស្រុក ទូទាំងខេត្តមណ្ឌលគិរី ។ តារាងនេះបង្ហាញថា ស្ថិតិក្នុងសំណាកដែលជ្រើសរើសចេញពីសិស្សចំនួន៣២៩៨នាក់ មាន ៧៤ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌ ខ)កំពុងបង្រៀនសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយទេ។ មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន ១៧នាក់(១៨៣ ដកនឹង ១៦៦) ។នេះសបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូ ចំនួន ១៧នាក់ផងដែរ។ ម្យ៉ាងទៀត គ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន១៧នាក់ (១៨៣ ដកនឹង ១៦៦) ដែរ។ នេះបញ្ជាក់ឱ្យឃើញថា ចំនួនគ្រូនៅតែខ្វះ។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះអនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងខេត្តមានវិធីច្រើនយ៉ាងដូចជា៖ (១) បង្កើននិយាមសិស្សថ្នាក់

លើសពី៤០នាក់ ក្នុងមួយថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា (២) ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀនមុខវិជ្ជាដែលគ្មានគ្រូឯកទេសនិង(៣)ជំរុញឱ្យគ្រូបង្រៀនត្រូវឯកទេសបង្រៀនជារបបម៉ោងបន្ថែម។ ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការខ្វះគ្រូ ដែលមានក្របខ័ណ្ឌកម្រិតមូលដ្ឋានដូចនេះក៏ដោយក៏មិនបញ្ជាក់ថា ខ្វះគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។

**ក្រាហ្វទី១០ ៖ ស្ថិតិ គ្រូជាក់ស្តែង តាមនិយាមថ្មី និងលើស ឬខ្វះគ្រូ**




ក្រាហ្វទី១០ បង្ហាញឱ្យឃើញពីការប្រៀបធៀប រវាងគ្រូបង្រៀនកម្រិតមូលដ្ឋានមានស្រាប់ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមនិយាមនៃការប្រើប្រាស់បុគ្គលិកអប់រំ ចំនួនគ្រូមុខវិជ្ជាដែលខ្វះមាន១០មុខវិជ្ជា គឺ ភាសាខ្មែរ ៥នាក់ ភាសាអង់គ្លេស៦នាក់ គណិតវិទ្យា៩នាក់ ផែនដីវិទ្យា១នាក់ ភូមិវិទ្យា៦នាក់ សីលធម៌ពលរដ្ឋ៤នាក់ កុំព្យូទ័រ៦នាក់ អប់រំសិល្បៈ៥នាក់ អប់រំសុខភាព៥នាក់ និងបំណិនជីវិតមូលដ្ឋាន៥នាក់។ ចំណែកឯមុខវិជ្ជាដែលលើសមានៈ រូបវិទ្យា៧នាក់ គីមីវិទ្យា១នាក់ ជីវវិទ្យា៩នាក់ ប្រវត្តិវិទ្យា៨នាក់ គេហ

វិទ្យា២នាក់ អប់រំកាយកីឡា៧នាក់ ប៉ុន្តែបើគិតតាមនិយាមខ្វះគ្រូរួម១៧នាក់នេះដោយសារតែមានមុខវិជ្ជាខ្លះលើស និងមុខវិជ្ជាខ្លះទៀតខ្វះ។ ដូចនេះការបែងចែក និងការប្រើប្រាស់គ្រូអនុវិទ្យាល័យនៅក្នុងខេត្តមណ្ឌលគិរីមិនទាន់បានសមស្របតាមនិយាមនៅឡើយទេ។ ហើយម្យ៉ាងវិញទៀតចំពោះមុខវិជ្ជា អប់រំសិល្បៈ អប់រំសុខភាពនិងបំណិនជីវិតតាមមូលដ្ឋាន គឺគ្មានគ្រូបង្រៀនមុខវិជ្ជាទាំងនេះគ្រប់សាលាតែម្តងសម្រាប់ខេត្តមណ្ឌលគិរីនេះ ។

ការស្រាវជ្រាវនេះ ក៏បានពិនិត្យស៊ីជម្រៅផងដែរទៅលើអថេរស្រុកនីមួយៗ ហើយលទ្ធផលដូចមានបង្ហាញខាងក្រោម៖

### ៤.២.២.២.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងក្រុងសែនមនោរម្យ

**តារាងទី៨៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងក្រុងសែនមនោរម្យ**

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | ៧៤៧ នាក់ | |
| ថ្នាក់ | ១៩ ថ្នាក់ | ១៥ ថ្នាក់ |
| ម៉ោង | ៧៤៧ម៉ោង | ៦០០ ម៉ោង |
| គ្រូ | ៤២ នាក់ | ៣៣ នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ២៨ នាក់ | |
| គ្រូលើស ឬខ្វះ | -១៤ នាក់ | -៥ នាក់ |

តារាងទី៨៖ នេះបង្ហាញថា ស្ថិតិសំណាកក្នុងក្រុងសែនមនោរម្យ មានសិស្សចំនួន៧៤៧នាក់ មាន ១៥ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង ២៨នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ១៩ថ្នាក់(៧៤៧ ចែកនឹង ៤០) និង តាមក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ ៧៤៧ម៉ោង (១៩ គុណ ៤០) ត្រូវការគ្រូចំនួន៤២នាក់(៧៤៧ចែក

១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៤ថ្នាក់ (១៩ ដកនឹង ១៥)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី១នេះ មិនទាន់គោរពបាននូវនិយាមសិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។មួយវិញទៀត កាលណាចំនួនថ្នាក់តិចជាងនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន ៩នាក់ (៤២ ដក ៣៣) ។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូ ចំនួន ៩នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន ១៤នាក់ (៤២ ដកនឹង ២៨) ដែរ។ នេះបញ្ជាក់ឱ្យឃើញថា ខ្វះគ្រូកាន់តែច្រើនបើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី ។ យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះ មានចំនួន ៥០នាក់ក្នុងមួយថ្នាក់ (៧៤៧ ចែកនឹង ១៥) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ៤០នាក់ក្នុងមួយថ្នាក់ ។ បើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនរហូតដល់២១ម៉ោងក្នុងមួយសប្តាហ៍ គឺលើសពីនិយាមដែលកំណត់ដោយក្រសួងអប់រំ ១៨ម៉ោង ក្នុងមួយសប្តាហ៍។

សរុបមកឃើញថាគ្រូដែលកំពុងបង្រៀនជាក់ស្តែងក្នុងក្រុងសែនមនោរម្យមានការខ្វះគ្រូ ដែលបណ្តាលឱ្យគ្រូនៅក្នុងក្រុងនេះត្រូវបង្រៀនម៉ោងបន្ថែម។

### ៤.២.២.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកអូររាំង

**តារាងទី៩៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកអូររាំង**

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | ២៦៩ នាក់ | |
| ថ្នាក់ | ៧ ថ្នាក់ | ៧ ថ្នាក់ |
| ម៉ោង | ២៦៩ម៉ោង | ២៤០០ ម៉ោង |
| គ្រូ | ១៥ នាក់ | ១៣ នាក់ |

| | | |
|---|---|---|
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១៦នាក់ | |
| គ្រូលើស ឬខ្វះ | ១នាក់ | -៣នាក់ |

តារាងទី៩៖ នេះបង្ហាញថា ស្ថិតិសំណាកក្នុងស្រុកអូររាំង មានសិស្សចំនួនជាក់ស្តែង២៦៩នាក់ មាន៧ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង ១៦នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ៧ថ្នាក់(២៦៩ ចែកនឹង ៤០) និង តាមក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ២៦៩ ម៉ោង(៧ គុណ ៤០) ត្រូវការគ្រូចំនួន១៥នាក់(២៦៩ចែក១៨) ថ្នាក់ជាក់ស្តែងដែលមានស្រាប់ស្មើ ថ្នាក់តាមនិយាម ឯគ្រូជាក់ស្តែង និងតាមនិយាមលើសខ្វះតិចតួច។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស ថ្នាក់របស់ស្រុកអូររាំងនេះ មានភាពសមស្របតាមនិយាមសិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។មួយវិញទៀត កាលណាចំនួនថ្នាក់តិចជាងនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែង ក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន ២នាក់ (១៥ ដក ១៣) ។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួនតិចតួចគឺ២ នាក់តែប៉ុណ្ណោះ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់លើសចំនួនគ្រូតាមនិយាមចំនួន ១នាក់ (១៦ ដកនឹង ១៥) ដែរ។

សរុបមកឃើញថា ការប្រើប្រាស់គ្រូមានភាពលម្អៀងតិចតួចបើធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

#### ៤.២.២.៤.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកកោះញែក

**តារាងទី១០៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកកោះញែក**

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៧៦៥ នាក់ | |
| ថ្នាក់ | ១៩ ថ្នាក់ | ១៨ ថ្នាក់ |

| | | |
|---|---|---|
| ម៉ោង | ៧៦៥ ម៉ោង | ៧២០ម៉ោង |
| គ្រូ | ៤៣ នាក់ | ៤០ នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ៣៩ នាក់ | |
| គ្រូលើសឬ ខ្វះ | -៤ នាក់ | -១ នាក់ |

តារាងទី១០៖ នេះបង្ហាញថា ស្ថិតិសំណាកក្នុងស្រុកកោះញែក មានសិស្សចំនួនជាក់ស្តែង៧៦៥នាក់ មាន ១៨ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង ៣៩នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ១៩ថ្នាក់(៧៦៥ ចែកនឹង ៤០) និង តាមក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៧៦៥ ម៉ោង(១៩ គុណនឹង ៤០) ត្រូវការគ្រូចំនួន៤៣នាក់(៧៦៥ចែកនឹង១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន១ថ្នាក់ (១៩ ដកនឹង ១៨)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកកោះញែកនេះ មានភាពលម្អៀងតិចតួចសមស្របតាមនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។មួយវិញទៀត កាលណាចំនួនថ្នាក់តិចជាងនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន ៣នាក់ (៤៣ ដកនឹង ៤០)។ សបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួនតិចតួចគឺ៣ នាក់តែប៉ុណ្ណោះ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ លើសចំនួនគ្រូតាមនិយាម៤នាក់ (៤៣ ដក ៣៩ )។

នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់គ្រូមានភាពលម្អៀងតិចតួចបើធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

### ៤.២.២.៥.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកពេជ្រាដា

**តារាងទី១១៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកពេជ្រាដា**

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៥៧០ នាក់ | |
| ថ្នាក់ | ១៤ ថ្នាក់ | ១២ថ្នាក់ |
| ម៉ោង | ៥៧០ ម៉ោង | ៤៨០ ម៉ោង |
| គ្រូ | ៣២ នាក់ | ២៧ នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ៣៧នាក់ | |
| គ្រូលើស ឬខ្វះ | ៥ នាក់ | ១០ នាក់ |

តារាងទី១១៖ នេះបង្ហាញថា ស្ថិតិសំណាកក្នុងស្រុកពេជ្រាដា មានសិស្សចំនួនជាក់ស្តែង ៥៧០ នាក់ មាន១២ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង ៣៧នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ១៤ថ្នាក់(៥៧០ចែកនឹង ៤០) និង តាមក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយ សប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៥៧០ ម៉ោង(១៤ គុណនឹង ៤០) ត្រូវការគ្រូចំនួន៣២នាក់ (៥៧០ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន២ថ្នាក់ (១៤ ដកនឹង ១២)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកពេជ្រាដានេះ មានភាពលម្អៀងតិចតួចសមស្របតាមនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។ មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាង ចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងចំនួនគ្រូតាមនិយាមផងដែរ នូវចំនួន ៥នាក់ (៣២ ដក ២៧)។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់

លើសចំនួនគ្រូតាមនិយាមចំនួន៥ នាក់ (៣៧ ដកនឹង ៣២) នេះបញ្ជាក់ឱ្យឃើញថា ចំនួនគ្រូនៅក្នុងស្រុកនេះលើស ។

### ៤.២.២.៦.ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកកែវសីមា

**តារាងទី១២៖ ស្ថិតិ សិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកកែវសីមា**

| ចំនួន | តាមនិយាម | តាមជាក់ស្តែង |
|---|---|---|
| សិស្ស | ៩៤៧ នាក់ | |
| ថ្នាក់ | ២៤ ថ្នាក់ | ២៣ ថ្នាក់ |
| ម៉ោង | ៩៤៧ ម៉ោង | ៩២០ ម៉ោង |
| គ្រូ | ៥៣នាក់ | ៥១ នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ៤៦ នាក់ | |
| គ្រូលើស ឬខ្វះ | -៧ នាក់ | -៥ នាក់ |

តារាងទី១២៖ នេះបង្ហាញថា ស្ថិតិសំណាកក្នុងស្រុកកែវសីមា មានសិស្សចំនួនជាក់ស្តែង ៩៤៧ នាក់ មាន២៣ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង ៤៦នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន ២៤ថ្នាក់( ៩៤៧ ចែកនឹង ៤០ ) និង តាមក្របខ័ណ្ឌកម្មវិធីសិក្សាចំណោះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយ សប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៩៤៧ ម៉ោង(២៤ គុណនឹង ៤០) ត្រូវការគ្រូចំនួន៥៣នាក់ (៩៤៧ចែកនឹង១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៧ថ្នាក់ (៥៣ ដកនឹង ៤៦)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកកែវសីមានេះ មានភាពលម្អៀងតិចតួចសមស្របតាមនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។ មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែង តិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងចំនួនគ្រូតាមនិយាមផងដែរ នូវ

ចំនួន ២នាក់ (៥៣ ដកនឹង ៥១)។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្ដែងតិចជាងចំនួនគ្រូតាមនិយាមចំនួន៧ នាក់ (៥៣ ដកនឹង ៤៦) នេះបញ្ជាក់ឱ្យឃើញថា ចំនួនគ្រូនៅក្នុងស្រុកនេះខ្វះច្រើនជាងគេ ។

### ៤.២.៣. ការកំណត់ពីតម្រូវការគ្រូ នៅអនុវិទ្យាល័យ (តាមនិយាម លេខ២៥៦)

អ្នកស្រាវជ្រាវបានពឹងផ្អែកទៅលើឯកសារយោងពីរជាស្ដង់ដារធៀប ដើម្បីឱ្យការវិភាគទិន្នន័យទាំងនេះមានភាពច្បាស់លាស់គឺ (១) សេចក្ដីណែនាំស្ដីពីការប្រើប្រាស់និយាមបុគ្គលិកអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា ២០០២) (២)កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា ២០០៦)។ អថេរសំខាន់ៗដែលនឹងត្រូវវិភាគទិន្នន័យនេះមានដូចជាៈ ចំនួនសិស្ស ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូដែលត្រូវបែងចែកជាបីប្រភេទគឺ (១) គ្រូតាមនិយាម (គ្រូដែលគិតតាមនិយាមប្រើប្រាស់បុគ្គលិកអប់រំ លេខ២៥៦) (២)គ្រូដែលកំពុងបង្រៀនជាក់ស្ដែង(គ្រូដែលកំពុងបង្រៀនជាក់ស្ដែងនៅតាមសាលាទូទាំងខេត្ត) (៣)តម្រូវការគ្រូតាមថ្នាក់ជាក់ស្ដែង (គ្រូដែលគិតតាមនិយាម ប៉ុន្តែយកតាមថ្នាក់ដែលទទួលបានជាក់ស្ដែង)។

**តារាងទី១៣ៈ ស្ថិតិសិស្ស ថ្នាក់ ម៉ោង គ្រូសរុបតាមនិយាមចាស់ និងតាមជាក់ស្ដែងទូទាំងខេត្ត**

| ចំនួន | តាមនិយាម | តាមជាក់ស្ដែង |
|---|---|---|
| សិស្ស | ៣២៩៨នាក់ | |
| ថ្នាក់ | ៧៣ ថ្នាក់ | ៧៤ ថ្នាក់ |
| ម៉ោង | ២៣៣៦ ម៉ោង | ២៣៦៨ ម៉ោង |
| គ្រូ | ១៣០ នាក់ | ១៣២ នាក់ |
| គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន | ១៦៦ នាក់ | |
| គ្រូលើស ឬខ្វះ | ៣៦ នាក់ | ៣៨ នាក់ |

តារាងទី១៣ បង្ហាញថា អនុវិទ្យាល័យ និងវិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយសរុប១៤សាលា ក្នុងក្រុង ស្រុកទាំងប្រាំទូទាំងខេត្តមណ្ឌលគិរីអ្នកស្រាវជ្រាវផ្តោតលើអថេរសំខាន់ៗដូចជាៈ ចំនួនសិស្ស ចំនួនថ្នាក់ ចំនួនម៉ោងនិងចំនួនគ្រូដែលត្រូវបែងចែកជាបីប្រភេទគឺ ចំនួនគ្រូតាមនិយាម(១៣០នាក់) ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង(១៦៦នាក់) តម្រូវការគ្រូតាមថ្នាក់ជាក់ស្តែង(១៣២នាក់)។ តារាងនេះបង្ហាញថា ស្ថិតិក្នុងសំណាកមានសិស្សសរុប៣២៩៨នាក់ មានថ្នាក់សរុប៧៤ និងគ្រូកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែង១៦៦នាក់ នៅក្នុងឆ្នាំសិក្សា២០១៩-២០២០នេះ។ បើតាមសេចក្តីណែនាំស្តីពីការប្រើប្រាស់និយាមបុគ្គលិកអប់រំលេខ២៥៦ ថ្នាក់មានតែ៧៣គឺ(៣២៩៨ចែកនឹង៤៥) យោងតាមកម្មវិធីសិក្សាគោលកម្រិតមូលដ្ឋានចំណេះទូទៅសម្រាប់មធ្យមសិក្សាបឋមភូមិក្នុងមួយថ្នាក់ត្រូវរៀន៣២ម៉ោងក្នុងមួយសប្តាហ៍នាំឱ្យម៉ោងសរុប(៧៣គុណនឹង៣២) ត្រូវការគ្រូចំនួន១៣០នាក់ (៣២៩៨ចែកនឹង១៨) តាមនិយាមគ្រូម្នាក់បង្រៀន១៨ម៉ោងក្នុងមួយសប្តាហ៍។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់ច្រើនជាងថ្នាក់តាមនិយាមចំនួន០១ថ្នាក់តែប៉ុណ្ណោះ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស ថ្នាក់ទូទាំងខេត្តមណ្ឌលគិរីសមស្រមតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ។ ម្យ៉ាងវិញទៀតចំនួនថ្នាក់ជាក់ស្តែងលើសចំនួនថ្នាក់តាមនិយាម នាំឱ្យតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏លើសចំនួនគ្រូតាមនិយាមផងដែរគឺលើសចំនួន០២នាក់(១៣២ដកនឹង១៣០) ហើយចំណុចសំខាន់ដែលអ្នកស្រាវជ្រាវរកឃើញនោះគឺ ចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានដែលកំពុងបង្រៀនជាក់ស្តែង លើសចំនួនគ្រូតាមនិយាមចំនួន៣៦នាក់ (១៦៦ដកនឹង១៣០)។

យ៉ាងណាមិញ ដើម្បីឱ្យការបង្រៀន និងរៀន ដំណើរការទៅបាន ការកំណត់និយាមសិស្សថ្នាក់តាមជាក់ស្តែងរបស់ខេត្តនេះ គឺមានចំនួន ៤៥នាក់ក្នុងមួយថ្នាក់(៣២៩៨ចែកនឹង៧៤)ដែលត្រឹមត្រូវតាមនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ៤៥នាក់ក្នុងមួយថ្នាក់ ។ នេះបញ្ជាក់ថា ខេត្តនេះ ការប្រើប្រាស់សិស្ស ថ្នាក់គឺសមស្របតាមនិយាមរបស់ក្រសួងអប់រំ យុវជននិងកីឡា។ វិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៤ម៉ោងក្នុងមួយសប្តាហ៍(៧៤គុណនឹង ៣២ ចែកនឹង ១៦៦)

តិចជាងនិយាមដែលកំណត់ដោយ ក្រសួង ១៨ម៉ោង ក្នុងមួយសប្តាហ៍ ។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់មានការលើសគ្រូផងដែរ ។

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានក្របខ័ណ្ឌកម្រិតមូលដ្ឋានដូចនេះក៏ដោយ ក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ ត្ួយ៉ាងដូចមានបង្ហាញក្នុងក្រាបទី១១។




## ក្រាហ្វទី១១ ៖ ស្ថិតិ គ្រូជាក់ស្តែង តាមមុខវិជ្ជា និងលើស ឬខ្វះគ្រូ

ក្រាហ្វទី១១បង្ហាញថាតាមមុខវិជ្ជា ភាសាខ្មែរលើស៣, ភាសាបរទេសលើស៥, គណិតខ្វះ១,រូបវិទ្យាលើស៨, គីមីវិទ្យាលើស២, ជីវវិទ្យាលើស១០, ផែនដីស្មើ, ភូមិវិទ្យាខ្វះ៣, ប្រវត្តិវិទ្យាលើស១១, កុំព្យូទ័រខ្វះ៥,សីលធម៌ខ្វះ៣, គេហវិទ្យាលើស៣, អប់រំកាយនិងកីឡាលើស៨, អប់រំសិល្បៈខ្វះ៤, អប់រំសុខភាពខ្វះ៤ និងបំណិនជីវិតតាមមូលដ្ឋានខ្វះ៤។

សរុបមកគ្រូតាមឯកទេសនីមួយៗ ឃើញថាមុខវិជ្ជាដែលលើសច្រើនជាងគេរួមមាន រូបវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងអប់រំកាយនិងកីឡា ដោយសារការបែងចែកមិនទាន់បានត្រឹមត្រូវតាមតម្រូវការ សាលាខ្លះខ្វះ សាលាខ្លះទៀតលើស។

### ៤.២.៤. ទស្សនៈរបស់នាយក/នាយិកាលើការប្រើប្រាស់គ្រូអនុវិទ្យាល័យ




**ក្រាហ្វទី១២៖ ការស្នើសុំគ្រូរយៈពេល៥ឆ្នាំចុងក្រោយ**

ក្រាហ្វទី១២បង្ហាញឱ្យឃើញថាតាមការស្រង់មតិរបស់នាយក/នាយិកាសាលាចំនួន១៤នាក់ក្នុងចំណោម១៤សាលា ក្នុងខេត្តមណ្ឌលគិរី ការស្នើសុំបន្ថែមគ្រូក្របខណ្ឌកម្រិតមូលដ្ឋាន(ក្របខ័ណ្ឌខ) រយៈពេល៥ឆ្នាំចុងក្រោយនេះ ១៤ភាគរយ ទទួលបានគ្រប់ចំនួន , ៧៩ភាគរយ ទទួលបានខ្លះ និង ៧ភាគរយ មិនទទួលបាន ។ បើគិតទៅលើភាគរយដែលខ្ពស់ជាងគេគឺទទួលបានខ្លះ លោកនាយក/នាយិកាតាម *សាលាដែលខ្វះគ្រូ បានមានប្រសាសន៍ថា មិនសូវមានគ្រូថ្មីចូលបន្ថែម គ្រូថ្មី មកតែ១ឆ្នាំ ឬ ២ឆ្នាំ ដូរចេញទៅវិញ* និងការជ្រើសរើសគ្រូបណ្តុះបណ្តាល និងបែងចែកគ្រូមានចំនួនកំណត់ ជាហេតុធ្វើអោយសាលាខ្លះលើស និងសាលាខ្លះទៀតខ្វះគ្រូ។

### ៤.២.៥.បញ្ហាប្រឈម និងដំណោះស្រាយរបស់នាយក/នាយិកាសាលាលើការប្រើប្រាស់គ្រូបង្រៀន

#### ក. បញ្ហាប្រឈមលើការប្រើប្រាស់គ្រូបង្រៀន

ចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀនក្នុងចំណោមនាយកទាំង១៤(៧៩%) បានលើកឡើងថា សាលារបស់គាត់ខ្វះគ្រូបង្រៀនធ្វើឱ្យពិបាកក្នុងការរៀបចំសិស្សឱ្យរៀនត្រូវតាមនិយាមកំណត់ របស់ក្រសួងអប់រំ មានគ្រូមិនគ្រប់ឯកទេស ឯកទេសខ្លះគ្រូច្រើនលើសពីតម្រូវការ ការផ្តល់គ្រូមកឱ្យសាលាពីសំណាក់មន្ទីរអប់រំយុវជន និងកីឡាខេត្តមិនត្រូវតាមតម្រូវការ គ្រូមានកន្លែងរស់នៅឆ្ងាយពីសាលារៀន គ្រូតាមឯកទេសមានមិនគ្រប់ ពិបាកក្នុងការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ គ្រូម្នាក់បង្រៀនពីរមុខវិជ្ជាឬច្រើនជាងនេះ គ្រូខ្លះបំពេញការងារមិនបានពេញលេញតាមការចាត់តាំង គ្រូមួយចំនួនតូចមកបង្រៀនយឺតម៉ោងនិងពុំមានកិច្ចតែងការបង្រៀនបានទៀងទាត់ប្រចាំសប្តាហ៍ គ្រូមួយចំនួនខ្វះមនសិកា គិតប្រយោជន៍ផ្ទាល់ជាធំ គ្រូខ្លះទៀតយកចិត្តទុកដាក់តែម៉ោងបង្រៀនបន្ថែមក្រៅពីម៉ោងរដ្ឋ គ្រូមួយចំនួនធំមានមុខរបរមួយទៀតនៅផ្ទះ គ្រូខ្វះចំណេះដឹងផ្នែក ICT និងប្រព័ន្ធអេឡិចត្រូនិច ។

លទ្ធផលខាងលើបង្ហាញថាបញ្ហាប្រឈម ដែលកើតមានឡើងក្នុងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិគឺដោយសារក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ធ្វើការបែងចែក និងផ្តល់គ្រូបង្រៀនទៅតាមគ្រឹះស្ថានមធ្យមសិក្សាមិនបានគ្រប់គ្រាន់តាមឯកទេស និងមិនបានត្រូវតាមតម្រូវការ ដោយសារការបណ្តុះបណ្តាលគ្រូនៅមានកម្រិត ហើយតំបន់ខ្លះមានអ្នកដែលកម្រិតចំណេះដឹងក្រោមសញ្ញាបត្រទុតិយភូមិ មិនអាចត្រូវបានប្រឡងចូលគ្រូក្របខ័ណ្ឌ។ សាលាខ្លះដែលស្ថិតនៅទីប្រជុំជន គឺសម្បូរគ្រូបង្រៀនលើសពីតម្រូវការ ចំណែកឯសាលាដែលនៅជនបទតែងតែជួបនូវបញ្ហាកង្វះគ្រូបង្រៀន។ ចំណែក (Kayode, 2011) ក៏បានរកឃើញដែរថាសាលានៅទីក្រុងមានចំនួនគ្រូបង្រៀនច្រើនជាងសាលានៅទីជនបទ ដោយសាលាមធ្យមសិក្សា មួយចំនួននៅជនបទ មានគ្រូបង្រៀនត្រឹមតែ៧

នាក់ប៉ុណ្ណោះដោយរាប់ទាំងនាយកសាលាផងដែរ ដូចនេះចំនួននេះមិនគ្រប់គ្រាន់សម្រាប់បង្រៀនសិស្សនោះទេ។

### ខ. ដំណោះស្រាយចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលកើតមានឡើងនៅក្នុងការប្រើប្រាស់គ្រូបង្រៀននៅសាលារបស់ខ្លួន នាយកសាលាភាគច្រើនបានចាត់តាំងគ្រូមុខវិជ្ជាផ្សេងទៅបង្រៀនមុខវិជ្ជាដែលខ្វះគ្រូ ដោយយកគ្រូផ្នែកវិទ្យាសាស្ត្រឱ្យជួយបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយគ្រូផ្នែកសង្គមជួយបង្រៀនផ្នែកសង្គម យកមន្ត្រីការិយាល័យទៅជួយបង្រៀន ជ្រើសរើសគ្រូដែលមានបទពិសោធបង្រៀនច្រើនឆ្នាំ មានចំណេះដឹងទូលំទូលាយ និងធ្វើការបំប៉នជាប្រចាំតាមរយៈការប្រជុំក្រុមបច្ចេកទេស១ខែម្តង រៀបចំកាលវិភាគបង្រៀនជាក់ស្តែង គ្រូម្នាក់បង្រៀន២ឬ៣ឬ៤ មុខវិជ្ជា ជំរុញឱ្យគ្រូបង្រៀនខិតខំស្រាវជ្រាវ( ទាំងមុខវិជ្ជាឯកទេសនិងមិនមែនឯកទេស ) ឱ្យគ្រូបង្រៀនជាលក្ខណៈម៉ោងបន្ថែមទៅតាមឯកទេសដែលខ្វះគ្រូ ហៅគ្រូដែលបំពេញការងារមិនបានល្អមកជួបប្រជុំដោះស្រាយបញ្ហានៃការបំពេញការងារ ប្រជុំ ណែនាំ លើកទឹកចិត្តបុគ្គលិកឱ្យគោរពពេលវេលា ដោយយោងទៅលើ សេចក្តីណែនាំរបស់ក្រសួងអប់រំ លេខ ៥៦ អយក ចំពោះសាលាដែលខ្វះបន្ទប់គឺខ្ចីបន្ទប់ និងខ្ចីគ្រូពីក្រោមកជួយការបង្រៀន។ ចំពោះវិទ្យាល័យមួយចំនួនគឺយកគ្រូឧត្តមជួយបង្រៀនបឋមភូមិ និងយកគ្រូមូលដ្ឋានជួយបង្រៀនទុតិយភូមិ។ ពេលខ្លះអនុវិទ្យាល័យអាចស្នើសុំគ្រូបង្រៀនពីបឋមសិក្សាមកជួយបង្រៀនម៉ោងបន្ថែម។

ម្យ៉ាងទៀត ដើម្បីដោះស្រាយបញ្ហាខាងលើនេះ នាយក/នាយិកាអនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងខេត្តមានវិធីសាស្ត្រដូចជា៖ បង្កើន និងបន្ថយនិយាមសិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀន និងរៀបចំបង្កើតរបបម៉ោងបន្ថែមសម្រាប់មុខវិជ្ជាលើសគ្រូ ចំណុចទាំងអស់នេះអាចប៉ះពាល់ដល់ការសិក្សារបស់សិស្សតាមមុខវិជ្ជាឯកទេសនីមួយៗ និងចំណាយថវិកាច្រើនទៅលើប្រាក់ម៉ោងបន្ថែមរបស់គ្រូ ប៉ុន្តែការរៀបចំបែបនេះអាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់សាលា។

### ៤.២.៦.មតិយោបល់បន្ថែមរបស់នាយក/នាយិកា លើការប្រើប្រាស់គ្រូបង្រៀន

ចំពោះមតិយោបល់ នាយក/នាយិកាលើការប្រើប្រាស់គ្រូបង្រៀនចំនួន១៤នាក់ ស្មើនឹង១០០% ក្នុងនោះ៧នាក់ ស្មើ៥០% បានមានយោបល់ថា ស្នើសុំផ្តល់គ្រូថ្មីបន្ថែមលើមុខវិជ្ជាដែលខ្វះ ដើម្បីដោះស្រាយឱ្យសាលាអាចដំណើរការទៅបានរលូន ចំនួនគ្រូ៥នាក់ស្មើ៣៦% បានលើកឡើងថាបង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ ឯ២នាក់ទៀត ស្មើ១៤% បានលើកឡើងថា បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនៅតាមសាលាបឋមសិក្សា ចំនួន៨៨សាលា និងអនុវិទ្យាល័យ១៤សាលា ទូទាំងខេត្តមណ្ឌលគិរីតាមជាក់ស្តែងដោយផ្អែកលើប្រធានបទ **«ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា» ករណីសិក្សាខេត្តមណ្ឌលគិរី** អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថា៖

ការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី មានស្ថានភាពខ្វះគ្រូតិចតួច តាមជាក់ស្តែង បើប្រើតាមនិយាមកំណត់របស់ក្រសួងអប់រំ ឃើញថាលើសគ្រូច្រើនគ្រប់ក្រុង/ស្រុក ដោយសារសិស្សនៅតាមកម្រិតថ្នាក់និមួយ មានចំនួនតិច ប៉ុន្តែតម្រូវការគ្រូបង្រៀនត្រូវមានគ្រប់កម្រិតថ្នាក់ (សាលាបឋមសិក្សា)។ ចំពោះសាលាអនុវិទ្យាល័យ វិញបើគិតតាមជាក់ស្តែង និងតាមនិយាមឃើញថាលើសគ្រូ តាមឯកទេសមួយចំនួន (រូប ជីវៈ ខ្មែរ ប្រវត្តិ គេហៈ ភាសាបរទេស និងអប់រំកាយនិងកីឡា) ដោយសារការបែងចែកគ្រូមិនទាន់បានត្រឹមត្រូវទៅតាមសំណើរបស់សាលា និងការផ្លាស់ប្តូរទីកន្លែងបម្រើការងារពីតំបន់ដាច់ស្រយាលទៅទីប្រជុំជន (បញ្ហាការស្នាក់នៅ និងការធ្វើដំណើរឆ្ងាយ និងពិបាក)។

ទស្សនៈយល់ឃើញរបស់នាយកនាយិកាលើការដោះស្រាយបញ្ហានានាទាក់ទងនឹងការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យនានាក្នុងខេត្តមណ្ឌលគិរីគឺ លោកនាយក/នាយិកាករណីខ្វះគ្រូបឋម ស្នើសុំគ្រូថ្មីបន្ថែម ប្រើប្រាស់គ្រូកិច្ចសន្យា ថ្នាក់គួប និងថ្នាក់ពីរពេល ប្រើគោលការណ៍ខ្ចីគ្រូ យកគ្រូខុសឯកទេសមកជួយបង្រៀនលើមុខវិជ្ជាដែលខ្វះ ករណីលើសស្នើសុំពង្រាយគ្រូ។

លទ្ធផលនៃការសិក្សាទៅលើផ្នែកបឋមសិក្សាឃើញថាសាលាទូទាំងខេត្តចំនួន៨៨សាលា បើតាមចំនួនថ្នាក់ជាក់ស្តែង៦៥៨ថ្នាក់ ខ្វះគ្រូ៧៦នាក់ ប៉ុន្តែបើតាមនិយាមអប្បបរមាគ្រូលើស១៨៣នាក់ ហើយ

បើតាមនិយាមអតិបរមាវិញលើសរហូតដល់២៦៨នាក់។ ចំណែកអនុវិទ្យាល័យវិញតាមទិន្នន័យទូទាំងខេត្ត បង្ហាញថា មានថ្នាក់សរុបជាក់ស្តែងចំនួន៧៤នាក់ និងសិស្សសរុបជាក់ស្តែងចំនួន៣២៩៨នាក់ បើកិតតាមនិយាមថ្មីលេខ៖២០ ខ្វះគ្រូចំនួន១៧នាក់ លើមុខវិជ្ជា ភាសាខ្មែរ ភាសាអង់គ្លេស គណិតវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋ កុំព្យូទ័រនិងអប់រំកាយនិងអប់រំសិល្បៈ អប់រំសុខភាព និងអប់រំបំណិនជីវិតតាមមូលដ្ឋាន ។ ប៉ុន្តែបើគិតតាមនិយាមចាស់លេខ៖ ២៥៦ វិញឃើថាមានការលើសគ្រូចំនួន៣៦នាក់ លើមុខវិជ្ជា ភាសាខ្មែរ ភាសាអង់គ្លេស រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា គេហវិទ្យា និងអប់រំកាយនិងកីឡាទៅវិញ ។ ចំពោះដំណោះស្រាយលើបញ្ហាលើស ឬខ្វះគ្រូ ខាងបឋមសិក្សាប្រើប្រាស់ គ្រូពីរពេល ថ្នាក់គួប និងគ្រូកិច្ចសន្យា ឯអនុវិទ្យាល័យវិញ ប្រើគោលការណ៍ខ្ចីគ្រូពីវិទ្យាល័យ និងគ្រូដែលមានស្រាប់ខុសឯកទេសជួយបង្រៀន។

សន្និដ្ឋានជារួមមកលទ្ធផលនេះសបញ្ជាក់ឱ្យឃើញថាការបែងចែកគ្រូ ឬពង្រាយគ្រូ និងចាត់ចែងតួនាទីភារកិច្ចនៅក្នុងខេត្តមណ្ឌលគិរីមិនទាន់សមស្របទៅតាមសេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំយុវជន និងកីឡានៅឡើយទេ។ ចំណែកឯការ ប្រើប្រាស់គ្រូអនុវិញក៏មិនទាន់បានចំមុខវិជ្ជាឯកទេស ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការបង្រៀន និងរៀនមានការថយចុះ។

## ៥.២ សំណូមពរ

បើទោះបីជាលទ្ធផលដែលបានសិក្សាបង្ហាញថា ការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនានាក្នុងខេត្តមណ្ឌលគិរី ស្ថិតក្នុងកម្រិតមួយមិនទាន់សមស្របយ៉ាងណាក៏ដោយក៏អ្នកស្រាវជ្រាវ សូមលើកឡើងនូវសំណូមពរមួយ ចំនួនដើម្បីកែលម្អចំណុចខ្វះខាត ដែលភាគីពាក់ព័ន្ធនានាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវរួមគ្នាដោះស្រាយជាប្រព័ន្ធក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

- ក្រសួងអប់រំ យុវជន និងកីឡា៖

- សូមបើកវគ្គបណ្តុះបណ្តាលដល់គណៈគ្រប់គ្រងសាលាទាំងអស់ដែលត្រូវបានតែងតាំង ពីវិធីសាស្ត្រគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀនដើម្បីឱ្យការដឹកនាំអង្គភាពសាលារៀនប្រព្រឹត្តិទៅដោយភាពរលូន និងមានប្រសិទ្ធភាព
- ជ្រើសរើសគ្រូបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិឱ្យបានគ្រប់ចំនួនតាមតម្រូវការរបស់សាលា
- ជ្រើសរើសគ្រូបង្រៀនទៅតាមមុខវិជ្ជាឯកទេសដែលកំពុងខ្វះឱ្យបានគ្រប់ចំនួន និងផ្តល់ទៅសាលាដែលកំពុងជួបនូវបញ្ហាខ្វះគ្រូបង្រៀន ។

❖ មន្ទីរអប់រំ យុវជននិងកីឡាខេត្តៈ

- បែងចែកគ្រូបង្រៀនឱ្យសមស្របតាមតម្រូវការរបស់សាលា
- ពិនិត្យឡើងវិញលើករណីផ្ទេរចេញ និងផ្ទេរចូលរបស់គ្រូ
- បែងចែកគ្រូបង្រៀនតាមឯកទេស ដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន។
- ស្នើដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចុះអធិការកិច្ចសាលារៀនជាប្រចាំ និងកែលម្អ ព្រមទាំងផ្តល់អនុសាសន៍រាល់ចំណុចខ្វះខាតរបស់សាលា
- ស្នើសុំអនុវញ្ញាតការផ្លាស់ចេញតែពីសាលាដែលលើសគ្រូ និងផ្ទេរចូលទៅសាលាដែលខ្វះគ្រូ

❖ គណៈគ្រប់គ្រងសាលាៈ

-បែងចែកគ្រូបង្រៀនឱ្យបានគ្រប់កម្រិតថ្នាក់ទៅតាមចំនួនសិស្ស
- រៀបចំគ្រូបង្រៀនឱ្យបានមានប្រសិទ្ធភាព ដោយការរៀបចំគ្រូត្រូវឯកទេសឱ្យអស់លទ្ធភាពទើបយកគ្រូដែលខុសឯកទេសមកជួយ តែត្រូវរៀបចំការបំប៉នគ្រូខុសឯកទេសបន្ថែមមុននឹងប្រើប្រាស់
- ពង្រឹងការងារអធិការកិច្ចឱ្យបានទៀងទាត់ ។

❖ គ្រូបង្រៀនៈ

- គោរពតាមការចាត់តាំងរបស់គណៈគ្រប់គ្រងសាលា និងបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ ដើម្បីឱ្យលទ្ធផលការងារប្រកបដោយប្រសិទ្ធភាព។

- គិតប្រយោជន៍រួមជាធំ (គឺគុណភាពនៃការបង្រៀនដើម្បីបានសិស្សដែលមានគុណភាព) ។

## ៥.៣. អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើការប្រើប្រាស់គ្រូបង្រៀនក្នុងកម្រិតមធ្យមសិក្សាបឋមភូមិក្នុងសាលាមួយចំនួនក្នុងខេត្តមណ្ឌលគិរី ហើយការប្រមូលទិន្នន័យគឺយកចេញពីទស្សនៈនាយកសាលាតែប៉ុណ្ណោះ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើ ចំណុចមួយចំនួនដូចខាងក្រោម៖

- សិក្សាលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅខេត្តមណ្ឌលគិរីដដែល ឬនៅខេត្តដទៃ។
- ស្រាវជ្រាវលើប្រធានបទដដែល តែជ្រើសរើសសំណាកធំជាងនេះ ដោយធ្វើការប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការសម្ភាសន៍ផ្ទាល់ជាមួយអ្នកឆ្លើយសំណួរតែម្តង។
- អាចធ្វើការសិក្សាស្រាវជ្រាវពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀនទៅលើការគ្រប់គ្រងរបស់នាយកសាលាកម្រិតមធ្យមសិក្សាបឋមភូមិ ។

# ឯកសារយោង ( REFERENCE )

1.Kayode, J. D. ( 2011 ). *Demand, Supply and Utilization of Secondary School Mediterranean Journal of Social Sciences, 69-77.*

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨). *សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំ ២០១៦-២០១៧.* ភ្នំពេញ.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ. (២០០៦). *ការងារគ្រប់គ្រង រដ្ឋបាល.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ. (២០១០). *ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន.* ភ្នំពេញ: ក្រសួងអបរំ យុវជន និងកីឡា.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ. (២០១៥). *គោលនយោបាយស្តីពីគ្រូបង្រៀន.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា. (២០១៥). *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស.* ភ្នំពេញ: ក្រសងអប់រំ យុវជន និងកីឡា.

ព្រះរាជក្រមលេខ០៦/នស/៩៤. (១៩៩៤). *ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ.

វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ. (១៩៩៨). *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ.

សេចក្តីណែនាំលេខ២០អយក.សណន. (២០១៨). *ស្តីពីនិយាមប្រើបុគ្គលិកអប់រំ.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

សេចក្តីណែនាំលេខ២៥៦អយក.សណន. (២០០២). *ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសំរាប់សាលាមត្តេយ្យ បឋមសិក្សា មធ្យមសិក្សាចំណេះទុទៅ និងសាលាគរុកោសល្យ.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

សេចក្តីណែនាំលេខ២៨. (២០១៤). *ស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

សេចក្ដីណែនាំលេខ៣៣អយក.សណន. (២០១៤). *ស្ដីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

សេចក្ដីណែនាំលេខ៥៣អយក.សណន. (២០១៩). *ស្ដីពីការគ្រប់គ្រងគ្រូបង្រៀន.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

# ឧបសម្ព័ន្ធ

## សាលាបឋមសិក្សាទាំង៨៨ ក្នុងខេត្តម

| I. **ស្រុកទី១** (**ក្រុងសែនមនោរម្យ**) | |
|---|---|
| ល.រ | ឈ្មោះសាលាបឋមសិក្សា |
| ១ | សាលាបឋមសិក្សា ហ.ស សែនមនោរម្យ |
| ២ | សាលាបឋមសិក្សា មូលនិធិសង្គម |
| ៣ | សាលាបឋមសិក្សា ឡៅកា |
| ៤ | សាលាបឋមសិក្សា ពូលូង |
| ៥ | សាលាបឋមសិក្សា ពូតាំង |
| ៦ | សាលាបឋមសិក្សា ពូត្រុំ |
| ៧ | សាលាបឋមសិក្សា ពូត្រុំថ្មី |
| ៨ | សាលាបឋមសិក្សា ពូត្រុំក្រុម៣ |
| ៩ | សាលាបឋមសិក្សា ស្រែអ៊ី |
| II. **ស្រុកទី២** (**កោះញែក**) | |
| ល.រ | ឈ្មោះសាលាបឋមសិក្សា |
| ១ | សាលាបឋមសិក្សា ហ.ស កោះញែក |
| ២ | សាលាបឋមសិក្សា ស្រែសង្គម |
| ៣ | សាលាបឋមសិក្សា ស្រែហ៊ុយ |
| ៤ | សាលាបឋមសិក្សា កោះម្សៀល |
| ៥ | សាលាបឋមសិក្សា ណងឃីលិក |
| ៦ | សាលាបឋមសិក្សា ស្រែជ្រៃ |
| ៧ | សាលាបឋមសិក្សា ឈូល |
| ៨ | សាលាបឋមសិក្សា រយ៉ក្រោម |
| ៩ | សាលាបឋមសិក្សា រវ៉ាក់ |
| ១០ | សាលាបឋមសិក្សា រយ៉លើ |
| ១១ | សាលាបឋមសិក្សា ក្ដោយ |

| | |
|---|---|
| ១២ | សាលាបឋមសិក្សា ម្នូរង៉ា |
| ១៣ | សាលាបឋមសិក្សា ស្រែរ៉ូង |
| ១៤ | សាលាបឋមសិក្សា ប៉ុងប៉ុង |
| ១៥ | សាលាបឋមសិក្សា ហ.ស មានជ័យ |
| ១៦ | សាលាបឋមសិក្សា គិរីរម្យ |
| ១៧ | សាលាបឋមសិក្សា ត្រពាំងព្រីង |
| ១៨ | សាលាបឋមសិក្សា អរប្បួនលើ |
| ១៩ | សាលាបឋមសិក្សា ស្រែជង |
| ២០ | សាលាបឋមសិក្សា សុខសាន្ត |
| ២១ | សាលាបឋមសិក្សា កែវពៅ |
| ២២ | សាលាបឋមសិក្សា ភូមិថ្មី |
| ២៣ | សាលាបឋមសិក្សា ស្រែធំ |
| ២៤ | សាលាបឋមសិក្សា ស្រែចាស់ |
| III. **ស្រុកទី៣(កែវសីមា)** | |
| ល.រ | ឈ្មោះសាលាបឋមសិក្សា |
| ១ | សាលាបឋមសិក្សា អូរអាម |
| ២ | សាលាបឋមសិក្សា ពន្លឺថ្មី |
| ៣ | សាលាបឋមសិក្សា ឡាប៉ាខេ |
| ៤ | សាលាបឋមសិក្សា ត្រពាំងផ្គេរ |
| ៥ | សាលាបឋមសិក្សា ឆ្នែង |
| ៦ | សាលាបឋមសិក្សា កែវសីមាហ៊ុន សែន |
| ៧ | សាលាបឋមសិក្សា អូររណា |
| ៨ | សាលាបឋមសិក្សា ពូចារ |
| ៩ | សាលាបឋមសិក្សា ស្រែអំពិល |
| ១០ | សាលាបឋមសិក្សា អូរប្រា |
| ១១ | សាលាបឋមសិក្សា ពូគង់ |
| ១២ | សាលាបឋមសិក្សា ហ្គាទី |

| | |
|---|---|
| ១៣ | សាលាបឋមសិក្សា ស្រែឈូក |
| ១៤ | សាលាបឋមសិក្សា ភូមិព្រះ |
| ១៥ | សាលាបឋមសិក្សា រណែង |
| ១៦ | សាលាបឋមសិក្សា ស្រែអណ្តោល |
| ១៧ | សាលាបឋមសិក្សា រយ៉ង |
| ១៨ | សាលាបឋមសិក្សា ស្រែអំពួយ |
| ១៩ | សាលាបឋមសិក្សា ខ្វង់ |
| ២០ | សាលាបឋមសិក្សា អូរតេ |
| ២១ | សាលាបឋមសិក្សា មេម៉ង់ |
| ២២ | សាលាបឋមសិក្សា ចុងផ្លាស់ |
| ២៣ | សាលាបឋមសិក្សា អូរគ្លែរ |
| ២៤ | សាលាបឋមសិក្សា ឡង់ណោះ |
| ២៥ | សាលាបឋមសិក្សា អូរតាំងឡាំង |
| ២៦ | សាលាបឋមសិក្សា ខ្វែង |
| ២៧ | សាលាបឋមសិក្សា ត្រាំកិត |
| IV. **ស្រុកទី៤(ពេជ្រាដា)** | |
| ល.រ | ឈ្មោះសាលាបឋមសិក្សា |
| ១ | សាលាបឋមសិក្សា ស្រែក្លេង |
| ២ | សាលាបឋមសិក្សា លែងឈូង |
| ៣ | សាលាបឋមសិក្សា ពូទិល |
| ៤ | សាលាបឋមសិក្សា វាលល្បោង |
| ៥ | សាលាបឋមសិក្សា ឡាំម៉េះ |
| ៦ | សាលាបឋមសិក្សា ស្រែអំពូម |
| ៧ | សាលាបឋមសិក្សា ពូក្រេង |
| ៨ | សាលាបឋមសិក្សា ក្រង់តេះ |
| ៩ | សាលាបឋមសិក្សា ពូរ៉ាប៉ែត |
| ១០ | សាលាបឋមសិក្សា ឡៅរមៀត |

| | |
|---|---|
| ១១ | សាលាបឋមសិក្សា អូរទេ |
| ១២ | សាលាបឋមសិក្សា កុមារមេគង្គ |
| ១៣ | សាលាបឋមសិក្សា ពូជ្រើចាង |
| ១៤ | សាលាបឋមសិក្សា ពូជ្រើ |
| ១៥ | សាលាបឋមសិក្សា អូរប៉ែយ |
| ១៦ | សាលាបឋមសិក្សា ដេអេ |
| ១៧<br>១៨ | សាលាបឋមសិក្សា អន្ទ្រងសែនជ័យ<br>សាលាបឋមសិក្សា បរគួង |
| V. **ស្រុកទី៥( អូររាំង )** | |
| ល.រ | ឈ្មោះសាលាបឋមសិក្សា |
| ១ | សាលាបឋមសិក្សា ពូហ្យាម |
| ២ | សាលាបឋមសិក្សា ដាក់ដាំ |
| ៣ | សាលាបឋមសិក្សា ប៊ូរ៉ាង |
| ៤ | សាលាបឋមសិក្សា ពូជូ |
| ៥ | សាលាបឋមសិក្សា ពូទ្រូលើ |
| ៦ | សាលាបឋមសិក្សា ពូទ្រូក្រោម |
| ៧ | សាលាបឋមសិក្សា ពូឡា |
| ៨ | សាលាបឋមសិក្សា រកា |
| ៩ | សាលាបឋមសិក្សា ដើមស្វាយ |
| ១០ | សាលាបឋមសិក្សា អណ្តូងក្រទឹង |

**បញ្ជីឈ្មោះសាលាអនុវិទ្យាល័យ និងវិទ្យាល័យដែលមានអនុវិទ្យាល័យនៅជាមួយ**

| | |
|---|---|
| I. **ស្រុកទី១( ក្រុងសែនមនោរម្យ )** | |
| ល.រ | ឈ្មោះអនុវិទ្យាល័យ និងវិទ្យាល័យ |
| ១ | វិទ្យាល័យ ហ.ស មណ្ឌលគិរី |
| ២ | អនុវិទ្យាល័យ សែនមនោរម្យ |
| II. **ស្រុកទី២( កោះញែក )** | |

| | |
|---|---|
| ១ | វិទ្យាល័យ ហ.ស កោះញែក |
| ២ | អនុវិទ្យាល័យ សុខសាន្ត |
| III. **ស្រុកទី៣(កែវសីមា)** | |
| ១ | វិទ្យាល័យ ហ.ស កែវសីមា |
| ២ | អនុវិទ្យាល័យ ឆ្នែង |
| ៣ | អនុវិទ្យាល័យ ស្រែព្រះ |
| ៤ | អនុវិទ្យាល័យ មេម៉ង់ |
| ៥ | អនុវិទ្យាល័យ ស្រែឈូក |
| IV. **ស្រុកទី៤(ពេជ្រាដា)** | |
| ១ | វិទ្យាល័យ ជ្រោះប៊ូស្រា |
| ២ | វិទ្យាល័យ អូរប្លាយ |
| ៣ | អនុវិទ្យាល័យទួលព្រីង |
| V. **ស្រុកទី៥(អូររាំង)** | |
| ១ | វិទ្យាល័យ អូររាំង |
| ២ | អនុវិទ្យាល័យ ដាក់ដាំ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

នាងខ្ញុំ ឈ្មោះ **ម៉ោញ វដ្ដា** ជានិស្សិត **ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣** ដែលកំពុងសិក្សានៅ វិទ្យាស្ថានជាតិអប់រំ ត្រូវបានចាត់តាំងឱ្យ ចុះប្រមូលទិន្នន័យ ស្ដីពីការប្រើប្រាស់គ្រូបង្រៀននៅសាលាអនុវិទ្យាល័យនានាក្នុងខេត្តមណ្ឌលគិរី។ ការប្រមូលទិន្នន័យនេះ ក្នុងគោលបំណងដើម្បីសរសេរនិក្ខេបបទបញ្ចប់វគ្គសិក្សា។

## ប្រធានបទស្រាវជ្រាវ

## ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សា ក្នុងប្រទេសកម្ពុជា

## ករណីសិក្សា៖ ខេត្តមណ្ឌលគិរី

### វត្ថុបំណងនៃការស្រាវជ្រាវ៖

១. រកឱ្យឃើញាពី ស្ថានភាពនៃការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន នៅតាមសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា។
២. រកឱ្យឃើញនូវដំណោះស្រាយសមស្របក្នុងការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន នៅតាមសាលាបឋមសិក្សានានាក្នុងប្រទេសកម្ពុជា ។

លេខទូរស័ព្ទ ៖ 068 68 86 97 / 096 47 24 771

### ការរក្សាការសម្ងាត់

ព័ត៌មានដែលទទួលបានពី លោក លោកស្រី នឹងត្រូវរក្សាការសម្ងាត់ ។ អត្តសញ្ញាណរបស់លោក លោកស្រី មិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។

## កម្រងសំណួរ

- **ការកំណត់ពីតម្រូវការ**

១. តើសាលា របស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា ?

- ក្នុងស្រុក................................................

២. តើសាលាបឋមសិក្សារបស់លោក~លោកស្រី មានឈ្មោះអ្វី ?

- សាលាបឋមសិក្សា...................................

៣. ទីតាំងសាលារៀន ៖ ☐តំបន់ក្រុង ☐ទីរួមស្រុក ☐តំបន់ជនបទ

៤. ចំនួនវេនរៀន ៖ ☐មួយវេន ☐ពីរវេន ☐បីវេន

៥. តើសាលា របស់លោក~លោកស្រី មានចំនួនសិស្សប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន ?

- ថ្នាក់ទី១៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី២៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី៣៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី៤៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី៥៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី៦៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់

៦. តើគ្រូ ក្របខ័ណ្ឌរដ្ឋ មានសរុបចំនួនប៉ុន្មាននាក់ ?( មិនរាប់បញ្ចូលគ្រូជាប់កិច្ចសន្យា )

- ចំនួនសរុប.......................នាក់ ស្រី......................នាក់

៧. តើគ្រូដែលកំពុងបង្រៀនជាក់ស្តែងចំនួនប៉ុន្មាននាក់ ?

- ចំនួនគ្រូក្របខ័ណ្ឌកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់
- ចំនួនគ្រូជាប់កិច្ចសន្យាកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

៨. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់ ?

- ចំនួនបន្ទប់រៀនជាក់ស្តែង......................បន្ទប់

៩. តើលោក~លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច ?

- ករណីលើស ..........................................................................................
  ..........................................................................................................
- ករណីខ្វះ ..............................................................................................
  ..........................................................................................................

- **ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ**

១.តើសាលាបឋមសិក្សារបស់លោក-លោកស្រី បានទទួលចំនួនគ្រូតាមការស្នើសុំដែរ ឬទេ រយៈពេល៥ឆ្នាំចុងក្រោយនេះ?

ចំនួនគ្រូទទួលបានតាមការស្នើសុំគឺ៖

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន

២.តើលោក លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?(ចម្លើយអាចលើសពី ១)

ករណីខ្វះ

☐ ផ្តល់គ្រូថ្មីបន្ថែម

☐ ផ្តល់ប្រាក់ម៉ោងបន្ថែម

☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍

☐ បង្កើនគ្រូបង្រៀនជាប់កិច្ចសន្យាទៅជាគ្រូកម្រិតបឋមសិក្សា ពេញសិទ្ធ

☐ ផ្សេងៗ.......................................................................................................

ករណីលើស

☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង

☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

☐ ផ្សេងៗ.......................................................................................................

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។

សូមអរគុណ!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

នាងខ្ញុំឈ្មោះ **ម៉ោញ វដ្ឋា** ជានិស្សិត **ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣** ដែលកំពុងសិក្សា នៅវិទ្យាស្ថានជាតិអប់រំ ត្រូវបានចាត់តាំងឱ្យ ចុះប្រមូលទិន្នន័យ ស្ដីពី ការប្រើប្រាស់គ្រូបង្រៀននៅតាមសាលាអនុវិទ្យាល័យនានាក្នុងខេត្តមណ្ឌលគិរី។ ការប្រមូលទិន្នន័យនេះ ក្នុងគោលបំណងដើម្បីសរសេរនិក្ខេបបទបញ្ចប់វគ្គសិក្សា។

លេខទូរសព្ទ ៖ 068 68 86 96 / 096 47 24 771

## ប្រធានបទស្រាវជ្រាវ ៖

## ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ ក្នុងប្រទេសកម្ពុជា

## ករណីសិក្សា៖ ខេត្តមណ្ឌលគិរី

### វត្ថុបំណងនៃការស្រាវជ្រាវ៖

១. រកឱ្យឃើញពី ស្ថានភាពនៃការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀន នៅតាមសាលាអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា។

២. រកឱ្យឃើញនូវ ដំណោះស្រាយសមស្រប នៃការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន នៅតាមសាសា អនុវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា ។

### ការរក្សាការសម្ងាត់

ព័ត៌មានដែលទទួលបានពី លោក លោកស្រី នឹងត្រូវរក្សាការសម្ងាត់ ។ អត្តសញ្ញាណរបស់លោក លោកស្រី មិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។

## កម្រងសំណួរ

● **ការកំណត់ពីតម្រូវការ**

1. តើសាលា របស់លោក-លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា?
   ក្នុងស្រុក..................................................
2. តើសាលា របស់លោក-លោកស្រី មានឈ្មោះអ្វី?
   ឈ្មោះសាលា៖..................................................
3. ទីតាំងសាលារៀន ៖ ☐តំបន់ក្រុង ☐ទីរួមស្រុក ☐តំបន់ជនបទ
4. ចំនួនវេនរៀន ៖ ☐មួយវេន ☐ពីរវេន ☐បីវេន
5. តើសាលារបស់លោក-លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?
   - ថ្នាក់ទី៧៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៨៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៩៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
6. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់?
   - ចំនួនបន្ទប់រៀនសរុប.................បន្ទប់ ប្រើប្រាស់ជាក់ស្តែង.................បន្ទប់
7. តើគ្រូ ក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ បានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់?
   - ចំនួនសរុប......................នាក់ ស្រី.....................នាក់
8. តើគ្រូកំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់ និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)
   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង....................នាក់ ស្រី................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | ចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន (គិតមួយឯកទេស) | ផ្សេងៗ |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិត | | |
| ៤ | រូប | | |
| ៥ | គីមី | | |
| ៦ | ជីវៈ | | |
| ៧ | ផែនដី | | |
| ៨ | ប្រវត្តិ | | |
| ៩ | ភូមិ | | |

| | | | |
|---|---|---|---|
| ១០ | សីលធម៌ ពលរដ្ឋ | | |
| ១១ | គេហវិទ្យា | | |
| ១២ | កុំព្យូទ័រ (ICT) | | |
| ១៣ | អប់រំកាយនិងកីឡា | | |
| ១៤ | អប់រំសិល្បៈ | | |
| ១៥ | អប់រំសុខភាព | | |
| ១៦ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

9. តើក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើនេះ តើមុខវិជ្ជាណាខ្លះដែលមិនបានអនុវត្ត?សូមបញ្ជាក់ពីមូលហេតុ ។

.................................................................................................................................

.................................................................................................................................

10. បើមុខវិជ្ជាមិនបានអនុវត្ត តើម៉ោងមុខវិជ្ជាទាំងនោះយកទៅបញ្ចូលជាមួយមុខវិជ្ជាណា?

.................................................................................................................................

.................................................................................................................................

11. តើលោក លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្ដេច?
    - ករណីលើស .......................................................................................................
      .......................................................................................................................
    - ករណីខ្វះ .........................................................................................................
      .......................................................................................................................

## ● ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ

1. តើសាលា របស់លោក~លោកស្រី បានទទួលចំនួនគ្រូតាមការស្នើសុំដែរ ឬទេរយៈពេល៥ឆ្នាំចុងក្រោយនេះ?

❖ ចំនួនគ្រូទទួលបានតាមការស្នើសុំគឺៈ

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ ផ្សេងៗ.................

2. តើលោក~លោកស្រី ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ?

.................................................................................................................................

.................................................................................................................................

3. តើលោក លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ? (ចម្លើយអាចលើសពី ១)

ករណីខ្វះ

☐ ផ្តល់គ្រូថ្មីបន្ថែម

☐ ផ្តល់ប្រាក់ម៉ោងបន្ថែម

☐ បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង

☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍

☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ

☐ ផ្សេងៗ.........................................................

ករណីលើស

☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង

☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

☐ ផ្សេងៗ..................................................................

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១៣៤ វជអ.វក

ថ្ងៃ ៧រោច ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក
"ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៥ វជអ. ឆក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វ៉ង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ិត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុជី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ម៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាឃលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន នីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ រដ្ឋា | ស | មណ្ឌលគិរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | រ៉ូច វី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្មស្ស | ស | ស្វាយរៀង |
| 29 | វ៉ែន សុជី | ប | ឧត្តរមានជ័យ |

ថ្ងៃ[illegible] ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"

- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ២៧៧ វជអ.សក

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ **"ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ"** នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សុគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សុគាន | ណាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុធី | ប | តាកែវ |

1

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី វឌ្ឍា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី វឌ្ឍា | ឱ សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នូវ វីរ៉ា | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ វឌ្ឍា | ស | មណ្ឌលគីរី |
| 25 | លោកបណ្ឌិត នូវ វីរ៉ា | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច វី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | រីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវេជអ "ដើម្បីជ្រាបជាព័ត៌មាន"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវេជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវេជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១៣៦ ចជអ.ដក

មន្ទីរ អ.យ.ក. ខេត្តមណ្ឌលគិរី
មកដល់ថ្ងៃទី..05...ខែ..08....ឆ្នាំ2020
ម៉ោង.............ចុះបញ្ជីលេខ..059.....

ថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០២០

**ជម្រាបជូន**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

កម្មវត្ថុ៖ ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

នាយកវិទ្យាស្ថានជាតិអប់រំ នឹង

បណ្ឌិត.ទេស៊ៀង សុវណ្ណា

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ